ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍

# ពិនិត្យឡើងវិញជាសកលតាមកាលកំណត់

# ជុំទី៤

ខែធ្នូ ឆ្នាំ២០២៣

## មាតិកា


ទំព័រ

**I. សេចក្តីផ្តើម** ........ ១

**II. វិធានការ និងសមិទ្ធផលសម្រេចបាន** ........ ១

១. ការផ្តល់សច្ចាប័ន និងការទទួលយកលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ ........ ១

២. កិច្ចសហប្រតិបត្តិការអន្តរជាតិ ........ ១

៣. ការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ........ ២

៤. គោលនយោបាយជាតិក្នុងវិស័យសិទ្ធិមនុស្ស ........ ២

៥. ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងកាត់បន្ថយភាពក្រីក្រ ........ ៣

៦. ការផ្គត់ផ្គង់ទឹកស្អាត ........ ៣

៧. សិទ្ធិទទួលបានការថែទាំសុខភាព ........ ៤

៨. ការទប់ស្កាត់ជំងឺរបេង និងជំងឺអេដស៍ ........ ៥

៩. អភិក្រមសុខាភិបាលពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀន ........ ៦

១០. សិទ្ធិទទួលបានការអប់រំ ........ ៦

១១. កំណែទម្រង់ដីធ្លី ........ ៨

១២. សមភាពយេនឌ័រ និងការរើសអើងផ្លូវភេទ ........ ៩

១៣. អំពើហិង្សាលើស្ត្រី និងកុមារ ........ ១០

១៤. អាពាហ៍ពិពាហ៍របស់ស្ត្រី និងកុមារ ........ ១១

១៥. ពលកម្មកុមារ ........ ១២

១៦. ការចុះបញ្ជីកំណើត ........ ១៣

១៧. យុត្តិធម៌អនីតិជន ........ ១៣

១៨. សិទ្ធិជនមានពិការភាព ........ ១៤

១៩. សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ........ ១៥

២០. ការប្រយុទ្ធប្រឆាំងការរើសអើងជនជាតិដើមភាគតិច និងជនជាតិភាគតិច ........ ១៦

២១. ការគ្រប់គ្រងគ្រោះមហន្តរាយ ........ ១៧

២២. កំណែទម្រង់ប្រព័ន្ធតុលាការ ........ ១៧

២៣. ឯករាជ្យភាពតុលាការ ........ ១៨

២៤. ការបង្កើតសាលាឧទ្ធរណ៍តំបន់ ........ ១៨

២៥. ការពន្លឿននីតិវិធីជំនុំជម្រះដើម្បីកាត់បន្ថយពេលវេលាឃុំខ្លួនបណ្តោះអាសន្ន ........ ១៨

២៦. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ........................................................ ១៨
២៧. ការប្រយុទ្ធប្រឆាំងអំពើពុករលួយ........................................................................ ១៩
២៨. ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ................................................................. ១៩
២៩. ការត្រួតពិនិត្យថ្នាក់ជាតិ ...................................................................................... ២១
៣០. ច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ............................................... ២១
៣១. ច្បាប់ស្ដីពីសហជីព........................................................................................... ២១
៣២. ច្បាប់ស្ដីពីទូរគមនាគមន៍ ...................................................................................... ២២
៣៣. ច្បាប់ស្ដីពីសិទ្ធិទទួលព័ត៌មាន ............................................................................... ២២
៣៤. ច្បាប់ស្ដីពីគណបក្សនយោបាយ ........................................................................... ២២
៣៥. សេរីភាពនៃការបញ្ចេញមតិ ................................................................................. ២២
៣៦. សកម្មជនសង្គមស៊ីវិល និងសមាជិកគណបក្សប្រឆាំង ........................................... ២៤
៣៧. លំហនយោបាយ និងប្រជាធិបតេយ្យ ................................................................. ២៤
៣៨. កំណែទម្រង់ការបោះឆ្នោត.................................................................................. ២៥

**III. បញ្ហាប្រឈម** ...................................................................................................... ២៥

**IV. សេចក្តីសន្និដ្ឋាន** .................................................................................................. ២៦

**ឯកសារយោង** ........................................................................................................... ២៧

## I-សេចក្តីផ្តើម

១-ការពិនិត្យរបាយការណ៍ជុំទី៣ របស់ប្រទេសកម្ពុជា បានធ្វើឡើងនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ដោយមានតំណាងប្រទេសចំនួន ៧៣ បានចូលរួមផ្តល់អនុសាសន៍ចំនួន ១៩៨ ដែលកម្ពុជាបានសម្រេចទទួលយកអនុសាសន៍ចំនួន ១៧៣ និងធ្វើការកត់សម្គាល់ចំនួន ២៥ ហើយត្រូវបានអនុម័តជាផ្លូវការដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៩។

២-គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក.) ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជា បានសហការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា (OHCHR) រៀបចំសិក្ខាសាលាថ្នាក់ជាតិនៅខែតុលា ឆ្នាំ២០១៩ ដើម្បីផ្សព្វផ្សាយនិងបែងចែកអនុសាសន៍ដែលបានទទួលយកជូនដល់ក្រសួង/ស្ថាប័នពាក់ព័ន្ធ។ សិក្ខាសាលានេះ មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធរួមមាន តំណាងមកពីស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល ព្រមទាំងស្ថានទូតមួយចំនួនប្រចាំប្រទេសកម្ពុជា។ ក្នុងខែតុលា ឆ្នាំ២០១៩ គ.ស.ម.ក. បានបញ្ជូនអនុសាសន៍ទាំងនោះជាផ្លូវការទៅក្រសួង/ស្ថាប័នពាក់ព័ន្ធដើម្បីអនុវត្ត។ បន្ថែមលើនេះ គ.ស.ម.ក. ក៏បានធ្វើការផ្សព្វផ្សាយរបាយការណ៍ និងអនុសាសន៍ជាបន្តបន្ទាប់ ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីអនុវត្តច្បាប់ នៅតាមមន្ទីរ/អង្គភាពជុំវិញខេត្តធំៗមួយចំនួន។

៣-របាយការណ៍ជុំទី៤នេះ ធ្វើឡើងដោយផ្អែកលើរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ ដែលកម្ពុជាបានចងក្រងឡើងក្នុងគោលបំណងតាមដានការអនុវត្តរបស់ក្រសួង/ស្ថាប័នមានសមត្ថកិច្ចក្នុងរយៈពេលពីរឆ្នាំ។ បន្ថែមលើនេះ ក៏មានកិច្ចប្រជុំពិភាក្សាជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធ និងកិច្ចពិគ្រោះយោបល់ជាមួយក្រុមអង្គការសង្គមស៊ីវិល ក្រោមកិច្ចសហការជាមួយ OHCHR។ របាយការណ៍នេះ បង្ហាញពីវិធានការ សមិទ្ធផលសម្រេចបាន និងបញ្ហាប្រឈមនានា ក្នុងការអនុវត្តអនុសាសន៍ដែលកម្ពុជាបានទទួលយក ចាប់ពីខែតុលា ឆ្នាំ២០១៩ ដល់ខែធ្នូ ឆ្នាំ២០២៣។

## II-វិធានការ និងសមិទ្ធផលសម្រេចបាន

### ១-ការផ្តល់សច្ចាប័ន និងការទទួលយកលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ

(អនុសាសន៍លេខ ២-១០)

៤-ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិចំនួន ៨ ក្នុងចំណោមសន្ធិសញ្ញាស្នូលចំនួន ៩ និងជារដ្ឋភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិចំនួន ៤ទៀត។ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងសិក្សាពីកត្តាច្បាប់ សេដ្ឋកិច្ច និងសង្គម ដើម្បីចូលជាសមាជិក ឬផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិ និងពិធីសារបន្ថែមនៃកតិកាសញ្ញា និងអនុសញ្ញាមួយចំនួនទៀត ជាអាទិ៍ អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តប្រវេសន៍និងសមាជិកគ្រួសាររបស់គេ អនុសញ្ញាឆ្នាំ១៩៥៤ ពាក់ព័ន្ធនឹងឋានៈជនគ្មានសញ្ជាតិ និងអនុសញ្ញាឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ និងពិធីសារបន្ថែមទី២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ពាក់ព័ន្ធនឹងការលុបបំបាត់ទោសប្រហារជីវិត។

### ២-កិច្ចសហប្រតិបត្តិការអន្តរជាតិ

(អនុសាសន៍លេខ ១៣ និង ១៩)

៥-ព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យមាន OHCHR ប្រចាំកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៩៣។ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជាបានបន្តសុពលភាពអនុស្សរណៈយោគយល់ជាមួយ OHCHR រយៈពេលពីរឆ្នាំទៀត រហូតដល់ខែធ្នូ ឆ្នាំ២០២៤ (លើកទី១២) ដែលស្តែងឱ្យឃើញយ៉ាងច្បាស់នូវការប្តេជ្ញាចិត្ត

ឥតងាករបស់កម្ពុជា ក្នុងការលើកកម្ពស់សិទ្ធិមនុស្ស តាមរយៈកម្មវិធីកិច្ចសហប្រតិបត្តិការបច្ចេកទេស។ កម្ពុជាបានទទួលយកអ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៣ ហើយនៅតែបន្តអាណត្តិយន្តការនេះរហូតមកដល់បច្ចុប្បន្ន។ កម្ពុជា តែងផ្តល់កិច្ចសហប្រតិបត្តិការបែបស្ថាបនាជាមួយយន្តការនីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស រួមទាំងការមកធ្វើទស្សនកិច្ចនៅកម្ពុជាស្របតាមស្ថានភាពជាក់ស្តែង។ ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានអនុញ្ញាតអ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិទទួលបន្ទុកការពារប្រឆាំងអំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ មកធ្វើទស្សនកិច្ចការងារនៅកម្ពុជា ពីថ្ងៃទី១០ដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣។ បន្ថែមលើនេះ កម្ពុជា ក៏បានរៀបចំកិច្ចសន្ទនាទ្វេភាគីស្តីពីសិទ្ធិមនុស្សជាមួយជប៉ុន និងចក្រភពអង់គ្លេស ផងដែរ។

## ៣-ការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស

(អនុសាសន៍លេខ ៣៤-៥៤)

**៦**-នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩ រាជរដ្ឋាភិបាល បានប្រគល់ភារកិច្ចជូន គ.ស.ម.ក. ក្នុងការបន្តរៀបចំសេចក្តីព្រាងច្បាប់នេះឡើងវិញ។ ដោយមានកិច្ចសហការពី OHCHR និងវេទិកាអាស៊ីប៉ាស៊ីហ្វិកនៃស្ថាប័នជាតិសិទ្ធិមនុស្ស (APF) ដែលមានមូលដ្ឋាននៅប្រទេសអូស្ត្រាលី ក្រោមកិច្ចសម្របសម្រួលពីស្ថានទូតនៃប្រទេសអូស្ត្រាលីប្រចាំកម្ពុជា, នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១ គ.ស.ម.ក. បានបញ្ចប់សេចក្តីព្រាងច្បាប់ដំបូងដែលមាន ៨ជំពូក និង ៣២មាត្រា។

**៧**-គ.ស.ម.ក. បានសហការជាមួយ OHCHR ដាក់សេចក្តីព្រាងច្បាប់នេះពិគ្រោះយោបល់ជាសាធារណៈ ចាប់ពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២១ ជាមួយក្រសួង/ស្ថាប័នរបស់រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា សហគមន៍ជនជាតិដើមភាគតិច អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងៗទៀតទាំងថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ព្រមទាំងបើកឱ្យមានការផ្តល់មតិយោបល់ជាសាធារណៈតាមរយៈទំព័រហ្វេសប៊ុក និងតេឡេក្រាមរបស់ គ.ស.ម.ក. ផងដែរ។ បច្ចុប្បន្ន គ.ស.ម.ក., OHCHR និង APF បានបញ្ចប់និងឯកភាពគ្នាថា សេចក្តីព្រាងច្បាប់នេះស្របតាមគោលការណ៍ទីក្រុងប៉ារីស ដោយ គ.ស.ម.ក. បានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ ដើម្បីបន្តនីតិវិធីសុំការអនុម័តពីសភាជាតិនៅពេលខាងមុខ។

## ៤-គោលនយោបាយជាតិក្នុងវិស័យសិទ្ធិមនុស្ស

(អនុសាសន៍លេខ ១, ១៤, ១២៨ និង ១៤១)

**៨**-រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងពន្លឿនការកែទម្រង់អភិបាលកិច្ច ការធ្វើទំនើបកម្មស្ថាប័នរដ្ឋ ការអភិវឌ្ឍប្រកបដោយចីរភាព បរិយាប័ន្ន សមធម៌ យុត្តិធម៌ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ រាជរដ្ឋាភិបាល ក៏បានដាក់ចេញនូវគោលដៅប្រកបដោយមហិច្ឆតារបស់ខ្លួន គឺការផ្លាស់ប្តូរឋានៈកម្ពុជាពីប្រទេសដែលមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទៅជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

**៩**-រាជរដ្ឋាភិបាល នៅតែបន្តយកចិត្តទុកដាក់លើកកម្ពស់និងការពារសិទ្ធិមនុស្ស តាមរយៈការពង្រឹងការអនុវត្តច្បាប់ ការបង្កើត ឬធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ការអប់រំអំពីច្បាប់និងសិទ្ធិមនុស្ស ជំរុញការអនុវត្តរាល់អនុសាសន៍សិទ្ធិមនុស្សនានាដែលទទួលបានពីគ្រប់ភាគីពាក់ព័ន្ធ និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយយន្តការសិទ្ធិមនុស្សជាតិ តំបន់ និងអង្គការសហប្រជាជាតិ ព្រមទាំងសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា។

## ៥-ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងកាត់បន្ថយភាពក្រីក្រ

(អនុសាសន៍លេខ ៥៦-៦៧)

**១០**-អត្រានៃភាពក្រីក្រក្នុងប្រទេសកម្ពុជា បានធ្លាក់ចុះគួរឱ្យកត់សម្គាល់ពីប្រមាណជា ៣៣,៨% នៅឆ្នាំ ២០០៩ មកត្រឹម ១៧,៨% នៅក្នុងឆ្នាំ២០១៩/២០។ ដើម្បីលើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋ ពិសេស នៅតាមទីជនបទ ក្រសួងមានសមត្ថកិច្ច បានដាក់ចេញនូវកម្មវិធីនានា រួមមាន ការកសាងហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវបេតុង ផ្លូវកៅស៊ូ ផ្លូវគ្រួសក្រហម ស្ពាន ប្រឡាយ លូ ស្រះទឹក និងសំណង់ជាច្រើនទៀតនៅតាម បណ្តាខេត្តជាប់ស្រយាល និងខេត្តមានជនជាតិដើមភាគតិចរស់នៅ ធ្វើឱ្យសេវាដឹកជញ្ជូនមានភាពងាយស្រួល ប្រសិទ្ធភាព សុវត្ថិភាព និងតម្លៃដឹកជញ្ជូនទាប។ ការស្ថាបនារចនាសម្ព័ន្ធទឹកស្អាតជនបទ អណ្តូងស្នប់អាប្រ៊ីដេ សាងសង់ស្រះទឹកសហគមន៍ អាងត្រងទឹកភ្លៀង ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ និងសាងសង់ចម្រោះ។ ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកស្អាតជនបទ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ រូបវន្តអនាម័យជនបទ ការផ្តល់បង្គន់អនាម័យ និងសេវាអនាម័យដល់គ្រួសារក្រីក្របានចំនួន ៨២,៤% ទូទាំង ប្រទេស ដែលជាការរួមចំណែកយ៉ាងខ្លាំងដល់ការកាត់បន្ថយជំងឺឆ្លង។ ការជំរុញបង្កើតការងារនិងមុខរបរនៅ ជនបទ ការលើកកម្ពស់និងការពង្រីកទីផ្សារបរទេសសម្រាប់ ផលិតផលកសិកម្ម ការជំរុញសកម្មភាពសេដ្ឋកិច្ច គ្រួសារនិងសាងសង់ផ្សារជនបទ រៀបចំការតាំងពិព័រណ៍ ផលិតផលសហគមន៍ជនបទ បណ្តុះបណ្តាលធនធាន មនុស្សនិងជំនាញអាជីព ជំរុញការអភិវឌ្ឍចម្រុះសម្រាប់សហគមន៍ជនបទ ការអភិរក្សនិងអភិវឌ្ឍន៍ជនជាតិ ដើមភាគតិច រួមទាំងការដាក់ចេញកម្មវិធីការងារស្តីពីការធ្វើកសិកម្ម ដំណាំបន្លែ ដំណាំឧស្សាហកម្ម ការចិញ្ចឹម សត្វ និងការធ្វើវារីវប្បកម្ម។

## ៦-ការផ្គត់ផ្គង់ទឹកស្អាត

(អនុសាសន៍លេខ ១៥០)

**១១**-រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាសេនាធិការ បានដាក់ចេញគោលនយោបាយ បទប្បញ្ញត្តិ និងកម្មវិធីនានា រួមមាន៖ (១). ផែនការពង្រីកវិសាលភាពនៃ ការផ្គត់ផ្គង់ទឹកស្អាត ដើម្បីចូលរួមសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០ (Cambodian Sustainable Development Goals (CSDGs) ដែលបានកំណត់ថា «ត្រឹមឆ្នាំ២០៣០ ត្រូវ សម្រេចការទទួលបានសកលកម្ម និងសមធម៌ទឹកបរិភោគ ដែលមានសុវត្ថិភាពនិងថ្លៃ សមរម្យសម្រាប់ប្រជាជន ទាំងអស់។ (២). ពង្រឹងលក្ខខណ្ឌនៃការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ៤យ៉ាង គឺ៖«ទឹកត្រូវមានគុណភាព សុវត្ថិភាព និរន្តរភាពនិងថ្លៃសមរម្យ» សំដៅធានាសុខភាពសាធារណៈ និងផលប្រយោជន៍ដល់គ្រប់ភាគី ជាពិសេស ប្រជាជន ដោយជួយឧបត្ថម្ភធនដល់ប្រជាជនក្រីក្រ។ (៣). ដាក់ឱ្យអនុវត្តគោលការណ៍ ណែនាំស្តីពីការផ្តល់ ឧបត្ថម្ភធនថ្លៃសិទ្ធិជាវទឹកសម្រាប់គ្រួសារក្រីក្រ នៅក្នុងខែកុម្ភៈ ឆ្នាំ២០២១។ នៅក្នុងខែឧសភា ឆ្នាំ២០១៧ ក្រសួងបានដាក់ឱ្យអនុវត្តគោលការណ៍រួមនៃការកំណត់ថ្លៃទឹកស្អាត ដោយកែប្រែពីការកំណត់ថ្លៃទឹកស្អាតតែ មួយប្រភេទទៅជាតារាងថ្លៃ ដែលបែងចែកទៅតាមកម្រិតនៃការប្រើប្រាស់ (Block Tariff) គឺអ្នកប្រើប្រាស់ តិចនឹងបង់ថ្លៃទឹកទាបជាងអ្នកប្រើប្រាស់ច្រើន។ ទន្ទឹមនេះ ក៏បានអនុវត្តវិធានការបញ្ចុះថ្លៃទឹកស្អាត និងការភ្ជាប់ បណ្តាញទឹកស្អាតជូនកម្មករ-កម្មការិនី និងសិស្ស និស្សិតស្នាក់នៅបន្ទប់ផ្ទះជួល ដើម្បីឱ្យអ្នកទាំងនោះទទួល បានទឹកស្អាតក្នុងថ្លៃសមរម្យ។

**១២**-ក្រសួងអភិវឌ្ឍន៍ជនបទ ដែលជាសេនាធិកាឱ្យរាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវទស្សនវិស័យផែនការ

យុទ្ធសាស្ត្រជាតិ ស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទឆ្នាំ២០១៤-២០២៥ ដែលបានកំណត់ថា «នៅឆ្នាំ ២០២៥ ប្រជាជនគ្រប់រូបនៅសហគមន៍ជនបទត្រូវមានការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព។» គិតត្រឹមឆ្នាំ២០២២ ទិន្នន័យអត្រាគ្របដណ្តប់ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទមានចំនួន ៨២,៧%។

**៧-សិទ្ធិទទួលបានការថែទាំសុខភាព**

(អនុសាសន៍លេខ ១៤០, ១៤២, ១៤៣, ១៤៧, ១៥៤, ១៥៥, ១៥៧ និង ១៥៨)

**១៣**-រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាចិត្តសម្រេចឱ្យបាននូវការគ្របដណ្តប់សុខភាពជាសកលសម្រាប់ប្រជាជនកម្ពុជា និងបានអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ២០១៦-២០២០ និងកំពុងបន្តអនុវត្តយ៉ាងសកម្មនូវក្របខណ្ឌគោលនយោបាយនានា រួមមាន៖ (១). បង្កើនចំណាយថវិកាជាតិលើសុខភាពសាធារណៈទៅតាមកំណើនសេដ្ឋកិច្ច និងសមត្ថភាពសារពើពន្ធសម្រាប់ផ្តល់សេវាសុខភាពជាអាទិភាពនៅតំបន់ជនបទ។ (២). បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយតម្លាភាព និងគណនេយ្យភាពនៅគ្រប់លំដាប់ថ្នាក់នៃប្រព័ន្ធសុខាភិបាល។ (៣). បង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុក្នុងការមករកសេវា និងប្រើប្រាស់សេវាថែទាំសុខភាពមានគុណភាព និង (៤). តម្រែតម្រង់ និងសុខដុមនីយកម្មជំនួយអភិវឌ្ឍន៍ជាមួយគោលនយោបាយ និងយុទ្ធសាស្ត្រសុខាភិបាល និងពង្រឹងការសម្របសម្រួលមូលនិធិដៃគូអភិវឌ្ឍន៍។ ការពង្រឹងវិស័យសុខាភិបាលបន្តផ្តោតលើអាទិភាពចម្បង៖ ទី១. កែលម្អស្ថានភាពសុខភាពប្រជាជនទូទៅឱ្យកាន់តែប្រសើរឡើងតាមរយៈការបន្តកាត់បន្ថយអាត្រាឈឺនិងស្លាប់ដោយសារជំងឺមិនឆ្លង ជំងឺសុខភាពផ្លូវចិត្ត ការបំពានគ្រឿងញៀន ជំងឺឆ្លងចម្បងៗ និងបញ្ហាសុខភាពសាធារណៈដទៃទៀត។ ទី២. ពង្រឹងភាពធន់នៃប្រព័ន្ធសុខាភិបាល ដោយផ្តោតលើការពង្រឹងសមត្ថភាពប្រព័ន្ធសន្តិសុខសុខភាព ប្រព័ន្ធផ្តល់សេវាសុខភាពប្រកបដោយនវានុវត្តន៍ ការពង្រឹងប្រព័ន្ធហិរញ្ញប្បទានសុខាភិបាល ប្រព័ន្ធគាំពារសុខភាពសង្គម ប្រព័ន្ធបណ្តុះបណ្តាលនិងគ្រប់គ្រងធនធានមនុស្ស ព្រមទាំងប្រព័ន្ធផ្គត់ផ្គង់ផ្សេងៗ និង ទី៣. ពង្រឹងយន្តការអភិបាលកិច្ចនិងនិយ័តកម្ម ប្រព័ន្ធតាមដាននិងវាយតម្លៃស្នាដៃប្រព័ន្ធសុខាភិបាល និងការសិក្សាស្រាវជ្រាវសុខាភិបាល។

**១៤**-ដើម្បីសម្រេចបាននូវគោលនយោបាយខាងលើ រាជរដ្ឋាភិបាល បានពង្រីកហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានដូចជា អគារ ឧបករណ៍ពេទ្យ បច្ចេកវិទ្យាវេជ្ជសាស្ត្រ បណ្តាញផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី ប្រព័ន្ធលូបង្ហូរទឹកកង្វក់ ឡដុតសំរាម/សំណល់វេជ្ជសាស្ត្រ បណ្តាញទំនាក់ទំនងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ មធ្យោបាយដឹកជញ្ជូន រួមជាមួយការគ្រប់គ្រងមានប្រសិទ្ធភាព បុគ្គលិកមានសមត្ថភាព មានឱសថ បរិក្ខារ និងឧបករណ៍ពេទ្យសមស្រប ព្រមទាំងមានការបង្ការហានិភ័យហិរញ្ញវត្ថុក្នុងការប្រើប្រាស់ និងសម្រួលដល់ដំណើរការផលិតសេវា ឱ្យមានបរិមាណគ្រប់គ្រាន់និងគុណភាពល្អ។

**១៥**-ត្រឹមខែធ្នូឆ្នាំ២០២២ មូលដ្ឋានសុខាភិបាលសាធារណៈទូទាំងប្រទេសមានមណ្ឌលសុខភាពចំនួន ១ ២៨៨ កន្លែង (ឆ្នាំ២០២០ មាន ១ ២៥០) ប៉ុស្តិ៍សុខភាពចំនួន ១២៥ (ឆ្នាំ២០២០ មាន ១២៩) និងមន្ទីរពេទ្យបង្អែកចំនួន ១៣២ (ឆ្នាំ២០២០ មាន ១២៨) ក្នុងនោះមានមន្ទីរពេទ្យជាតិចំនួន ១២ មន្ទីរពេទ្យបង្អែករាជធានី-ខេត្តចំនួន ២៥កន្លែង និងមន្ទីរពេទ្យបង្អែកក្រុង-ស្រុក-ខណ្ឌចំនួន ៩៥ នៅក្នុងស្រុកប្រតិបត្តិចំនួន ១០៣ នៃរាជធានី-ខេត្តទាំង ២៥ ទូទាំងប្រទេស។ មន្ទីរពេទ្យបង្កើតបន្ថែមថ្មីមាន៖ មន្ទីរពេទ្យត្បូងឃ្មុំ មន្ទីរពេទ្យហ្លួងម៉ែ មន្ទីរពេទ្យតេជោសន្តិភាព និងមន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម និងមន្ទីរពេទ្យបង្អែកស្រុកចំនួន ៥ទៀត ដែលបានដំឡើងមុខងារពីមណ្ឌលសុខភាពមានគ្រែឱ្យទៅជាមន្ទីរពេទ្យបង្អែក ដូចជា មន្ទីរពេទ្យ

បង្អែកបរិលខេត្តបាត់ដំបង មន្ទីរពេទ្យបង្អែកសំបូរខេត្តក្រចេះ មន្ទីរពេទ្យបង្អែកព្រែកប្រសព្វខេត្តក្រចេះ មន្ទីរពេទ្យបង្អែកកែវសីមាខេត្តមណ្ឌលគិរី និងមន្ទីរពេទ្យបង្អែកជាំក្សាន្តខេត្តព្រះវិហារ។

**១៦**-របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០១៨-២០២២ បង្ហាញថា អត្រាមរណភាពរបស់មាតា ទារក និងកុមារអាយុក្រោម៥ឆ្នាំ បន្តធ្លាក់ចុះ ក្នុងនោះមរណភាពមាតាធ្លាក់ចុះពី ១៧០ មកនៅ ១៥៤ ក្នុងទារកកើតរស់ ១០០ពាន់នាក់។ មរណភាពទារកអាយុពី ០-២៧ថ្ងៃ បានធ្លាក់ចុះពី ១៨ មកនៅ ០៨ ក្នុងទារកកើតរស់ ១ពាន់នាក់ និងមរណភាពកុមារអាយុក្រោម៥ឆ្នាំ បានធ្លាក់ចុះពី ៣៦ មកនៅ ១២ ក្នុងទារកកើតរស់ ១០០ពាន់នាក់ ហើយការពិនិត្យផ្ទៃពោះលើកទី២ មានការកើនឡើងរហូតដល់ ៩៨,៥៤%។ មូលដ្ឋានសុខាភិបាល ដែលផ្តល់សេវាដល់ស្ត្រីរងគ្រោះដោយអំពើហិង្សាមានចំនួន ១៦៩កន្លែង សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមានចំនួន ១ ៣០៤កន្លែង ការកើនឡើងនៃមូលដ្ឋានសុខាភិបាលដែលអាចផ្តល់សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភពមូលដ្ឋានមានចំនួន ៧១កន្លែង និងមូលដ្ឋានសុខាភិបាលដែលអាចផ្តល់សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភពពេញលេញមានចំនួន ៤០កន្លែង នៅទូទាំងប្រទេស។ ក្រសួងសុខាភិបាលសហការជាមួយក្រសួងកិច្ចការនារី បានបង្កើតនិងប្រកាសដាក់ឱ្យដំណើរការកន្លែងផ្តល់សេវាចម្រុះ ជួយដល់ជនរងគ្រោះដោយអំពើហិង្សាក្នុងមន្ទីរពេទ្យបង្អែកខេត្តចំនួន៦។

## ៨-ការទប់ស្កាត់ជំងឺរបេង និងជំងឺអេដស៍

(អនុសាសន៍លេខ ១៥៩ និង ១៦០)

**១៧**-ផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺរបេងឆ្នាំ២០២១-២០៣០ ដែលជាផែនការលើកទី៥ សម្រាប់ប្រយុទ្ធប្រឆាំងជំងឺរបេងក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅស្រាវជ្រាវរកជំងឺរបេង និងផ្តល់ការព្យាបាលដោយឥតបង់ថ្លៃ។ អត្រាព្យាបាលជោគជ័យនៃជំងឺរបេងត្រូវរក្សាបានខ្ពស់លើសពី ៩០% ក្នុងរយៈពេល២២ឆ្នាំជាប់ៗគ្នា។ ជាក់ស្តែងក្នុងឆ្នាំ២០២២ អត្រាព្យាបាលជោគជ័យ ៩៦% ដែលលើសពីគោលដៅចំណុចដែលបានកំណត់ត្រឹមតែ ៩០%។ សេវាព្យាបាលជំងឺរបេងមាននៅថ្នាក់ជាតិ មន្ទីរពេទ្យបង្អែកខេត្តចំនួន ២៥ មន្ទីរពេទ្យបង្អែកស្រុកនៃការិយាល័យស្រុកប្រតិបត្តិចំនួន ១០៣ និងក្នុងមណ្ឌលសុខភាពចំនួន ១ ២៨៨ ដែលប្រជាជនអាចស្វែងរកសេវានេះនៅជិតផ្ទះពួកគេរស់នៅទូទាំងប្រទេស។ បណ្តាញការងាររបេងនៅសហគមន៍ ដែលគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល បានធ្វើការយ៉ាងជិតស្និទ្ធជាមួយមណ្ឌលសុខភាពដោយមានអ្នកស្ម័គ្រចិត្ត២នាក់ក្នុងមួយភូមិ ដែលត្រូវបានបណ្តុះបណ្តាលដើម្បីបញ្ជូនអ្នកជំងឺរបេង ដឹកជញ្ជូនកំហាកសម្រាប់ធ្វើរោគវិនិច្ឆ័យជំងឺរបេង និងទទួលថ្នាំរបេងពីមណ្ឌលសុខភាពផ្តល់ជូនអ្នកជំងឺ។ ជារួម ការគ្របដណ្តប់សេវាជំងឺរបេងមាន ១០០% នៃគ្រប់មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពសហគមន៍ទូទាំងប្រទេស។ មានបណ្តាញមន្ទីរពិសោធន៍របេងចំនួន ២២០កន្លែង និងម៉ាស៊ីនជិនអិចស្ពឺតចំនួន ៨៨កន្លែង។

**១៨**-គិតត្រឹមខែធ្នូ ឆ្នាំ២០២២ អ្នកផ្ទុកមេរោគអេដស៍មានចំនួនសរុប ៦៤ ២០៩នាក់ ក្នុងនោះមានកុមារចំនួន ២ ៩៨៣នាក់។ ក្នុងចំណោមអ្នកជំងឺអេដស៍សកម្មទាំងអស់ ដែលមកទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅសេវាព្យាបាលជំងឺអេដស៍ មានអ្នកជំងឺ ៩៩,៤៨% (៦៤ ១៩៣/៦៤ ២០៩)។ ៩៧,៥៧% នៃអ្នករស់នៅជាមួយមេរោគអេដស៍កំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ បានធ្វើតេស្ត Viral Load និងមានលទ្ធផល Viral Load Suppressed នៅឆ្នាំ២០២២។ មានអ្នកជំងឺអេដស៍ ៨២,៩១% (៥៣ ២៣៩/៦៤ ២០៩) បានទទួលការស្រាវជ្រាវរកជំងឺរបេង ក្នុងនោះ ១,០៤% (៥៥៥/៥៣ ២៣៩) រកឃើញថាមានកើតជំងឺរបេង។ សេវាថែទាំនិងព្យាបាលជំងឺឱកាសនិយម និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បាន

កើនឡើងដល់ ៧១កន្លែងក្នុង ២៥ រាជធានី-ខេត្ត ដោយ ៦៩កន្លែង ស្ថិតនៅក្រោមការគ្រប់គ្រងដោយសេវាសុខភាពសាធារណៈ និង ២កន្លែងទៀតដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាល។

## ៩-អតិក្រមសុខាភិបាលពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀន

(អនុសាសន៍លេខ ១៥៦)

**១៩**-មាត្រា១០៥-១០៩ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ បានផ្តល់ជម្រើសនិងលើកទឹកចិត្តអ្នកប្រើ និងអ្នកញៀនគ្រឿងញៀនឱ្យទទួលយកការព្យាបាលនិងស្តារនីតិសម្បទា។ តាមរយៈគោលការណ៍នេះ អ្នកប្រើ និងអ្នកញៀនគ្រឿងញៀនទទួលបានការថែទាំសុខភាពទាំងផ្លូវកាយ ផ្លូវចិត្ត ការអប់រំទូទៅ ការបណ្តុះបណ្តាលបំណិនជីវិត ការព្យាបាលនិងស្តារនីតិសម្បទា និងការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ ដែលអាចជាមូលដ្ឋានសម្រាប់ពួកគាត់បង្ការការលាប់ទៅប្រើគ្រឿងញៀនឡើងវិញ ក៏ដូចជាមូលដ្ឋានក្នុងការប្រកបរបរចិញ្ចឹមជីវិតផងដែរ។ បន្ថែមលើនេះ រាជរដ្ឋាភិបាល បាននិងកំពុងបង្កើនការគ្របដណ្តប់ និងការទទួលបានសេវាផ្តល់ប្រឹក្សាសេវាសុខភាពផ្លូវចិត្ត និងការបន្សាបគ្រឿងញៀន ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដោយ ស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍។

**២០**-ក្នុងឆ្នាំ២០២៣ គិតត្រឹមខែកញ្ញា រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំសេវាពិនិត្យព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀនបានចំនួន ៤៥៤កន្លែង ដែលក្នុងនោះមានមន្ទីរពេទ្យជាតិ ២កន្លែង មន្ទីរពេទ្យរាជធានី-ខេត្ត ២៥កន្លែង មន្ទីរពេទ្យបង្អែក ៧២កន្លែង និងមណ្ឌលសុខភាព ៣៥៥កន្លែង ហើយក្នុងរយៈពេល ៩ខែនៃឆ្នាំ២០២៣នេះ បានផ្តល់សេវាពិនិត្យ និងព្យាបាលអ្នកញៀនគ្រឿងញៀនបានចំនួន ២ ៧៥៤នាក់ (ស្រី ១ ០១៧នាក់)។ ចំពោះអ្នកញៀនគ្រឿងញៀនប្រភេទហេរ៉ូអ៊ីន (ពពួកអាភៀន) រាជរដ្ឋាភិបាលបានរៀបចំផ្តល់សេវាព្យាបាលជំនួសដោយមេតាដូន (Methadone) នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងមន្ទីរពេទ្យបង្អែកមានជ័យក្នុងរាជធានីភ្នំពេញ ដែលកន្លងមកបានផ្តល់សេវាអ្នកញៀនគ្រឿងញៀនប្រភេទហេរ៉ូអ៊ីនបានចំនួន ១៣១នាក់ (ស្រី ១០នាក់)។

**២១**-ក្នុងគោលបំណងកាត់បន្ថយគ្រោះថ្នាក់នានាពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀន ពិសេសគ្រោះថ្នាក់នៃការចម្លងពេគអេដស៍/ជំងឺអេដស៍ និងរោគឆ្លងតាមឈាមផ្សេងៗទៀត រាជរដ្ឋាភិបាលកម្ពុជា បានបន្តអនុញ្ញាតឱ្យអង្គការជាដៃគូអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ដោយបានជួបនិងផ្តល់ប្រឹក្សាដល់អ្នកញៀនគ្រឿងញៀនបានចំនួន ៦២១នាក់ (ស្រី ១១២នាក់) ហើយបានផ្តល់កម្មវិធីម្ជុល/សឺរ៉ាំងស្អាត ក្នុងរយៈពេល៦ខែកន្លងទៅនេះអស់ចំនួន ៦០៣ ៧៣០ដើម និងបានប្រមូលម្ជុល/សឺរ៉ាំងប្រើប្រាស់រួច ដើម្បីដុតរំលាយចោលបានប្រមាណជា ៤៦៦ ២៣៩ដើម ស្មើនឹង ៧៨% នៃម្ជុល/សឺរ៉ាំងស្អាតដែលបានចែក។ ជារួម រាជរដ្ឋាភិបាលនៅតែបន្តយកចិត្តទុកដាក់ទាំងផ្លូវច្បាប់ និងការផ្តល់សេវាជួយសង្គ្រោះ ដើម្បីឱ្យអ្នកប្រើនិងអ្នកញៀនបានទទួលជម្រើសសមស្រប និងទទួលបានសេវាផ្តល់ប្រឹក្សា ពិនិត្យព្យាបាល ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មដែលមានលក្ខណៈស្របតាមបទដ្ឋានបច្ចេកទេស។

## ១០-សិទ្ធិទទួលបានការអប់រំ

(អនុសាសន៍លេខ ១៤០, ១៤២-១៤៦, ១៦១-១៧០ និង ១៨៧)

**២២**-រាជរដ្ឋាភិបាលកម្ពុជា យកចិត្តទុកដាក់ខ្ពស់លើវិស័យអប់រំដោយផ្តល់ការអប់រំផ្នែកមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សានៅសាលារៀនសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ និងបានកំណត់ថាប្រជាពលរដ្ឋត្រូវទទួលបានការអប់រំយ៉ាងតិច៩ឆ្នាំ និងធ្វើការបណ្តុះបណ្តាលធនធានមនុស្ស និងគ្រូបង្រៀន

ឱ្យមានគុណភាពខ្ពស់ទាំងផ្នែកសមត្ថភាព បច្ចេកទេស និងសីលធម៌។ ទន្ទឹមនឹងការផ្តល់លទ្ធភាពទទួលបានការអប់រំ រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ដល់ការលើកកម្ពស់គុណភាពអប់រំឱ្យកាន់តែប្រសើរឡើងថែមទៀត ដោយបានដាក់ចេញនូវវិធានការគន្លឹះចំនួន៤។ ដើម្បីឆ្លើយតបទៅនឹងវិធានការគន្លឹះទាំងនេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវអាទិភាពស្នូលចំនួន ៨ រួមមាន៖ (១). ការពង្រឹងអភិបាលកិច្ចសាលារៀន, (២). ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស, (៣). ការលើកកម្ពស់សុខភាពសិក្សាដោយយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា, (៤). ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោកភាពជាដៃគូរដ្ឋ និងសហគមន៍ ដើម្បីការអប់រំ, (៥). ការអប់រំឌីជីថល, (៦). ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា, (៧). ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព និង (៨). ការអភិវឌ្ឍការអប់រំកាយ និងកីឡា។

**២៣**-រាជរដ្ឋាភិបាលកម្ពុជា បានដំឡើងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភទៅតាមប្រភេទ និងឋានន្តរក្រមដល់គ្រូបង្រៀនក្របខណ្ឌរដ្ឋចាប់ពីខែមេសាឆ្នាំ២០១៩ សម្រាប់គ្រូបង្រៀនចេញថ្មីទទួលបានបៀវត្សអប្បបរមាចន្លោះពី ៣០០ ទៅ ៣៥០ដុល្លារអាមេរិក និងប្រាក់ឧបត្ថម្ភសម្រាប់តំបន់ជួបការលំបាក ឬដាច់ស្រយាលចន្លោះពី ២០ ទៅ ៣០ដុល្លារអាមេរិកក្នុងមួយខែ។

**២៤**-ដើម្បីផ្តល់លទ្ធភាពទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ធ្វើការពង្រីកហេដ្ឋារចនាសម្ព័ន្ធសាលារៀនឱ្យកាន់តែទៅជិតនឹងលំនៅឋានរបស់ប្រជាពលរដ្ឋ។ ជាលទ្ធផល នៅទូទាំងប្រទេសមានសាលាមត្តេយ្យសិក្សាគ្រប់រូបភាព ៨ ៦០៧សាលា/កន្លែង សាលាបឋមសិក្សា ៨ ០៦៧ អនុវិទ្យាល័យ ១ ៣៤០ វិទ្យាល័យ ៨១៦ វិទ្យាល័យចំនេះទូទៅនិងបច្ចេកទេស ១៩ និងគ្រឹះស្ថានឧត្តមសិក្សា ១១០។ គ្រូមត្តេយ្យសិក្សាមាន ៥ ៨៦៨នាក់ គ្រូបឋមសិក្សា ៥៧ ៦០៨នាក់ គ្រូបង្រៀនកម្រិតមូលដ្ឋាន ៣៣ ៦៥៣នាក់ គ្រូបង្រៀនកម្រិតឧត្តម ១៨ ៤៥៤នាក់ និងគ្រូបង្រៀននៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ១៦ ៤៧១នាក់។

**២៥**-ក្នុងការលើកកម្ពស់គុណភាពអប់រំ រាជរដ្ឋាភិបាល បានជំរុញការបណ្តុះបណ្តាលសមត្ថភាពគ្រូឧទ្ទេសគ្រូមុខវិជ្ជា អំពីវិធីសាស្ត្រវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស វិធីសាស្ត្របង្រៀន និងបច្ចេកវិទ្យាព័ត៌មាន ដូចជាការបង្រៀនអំណាន និងគណិតវិទ្យាថ្នាក់ដំបូងនៅបឋមសិក្សា និងវិធីសាស្ត្របង្រៀនតាមបែបរិះរក វិធីសាស្ត្របង្រៀនផ្តោតលើបញ្ញត្តិនៅកម្រិតមធ្យមសិក្សា រួមមាន ការផ្តល់ប្រឹក្សាគរុកោសល្យ ដើម្បីពង្រឹងដល់ការអនុវត្តរបស់គ្រូបង្រៀន។ ការផលិតវីដេអូបម្រើឱ្យការបង្រៀននិងការរៀនពីចម្ងាយ ផលិតសន្លឹកកិច្ចការសម្រាប់សិស្សស្វ័យសិក្សានិងវាយតម្លៃការសិក្សា រៀបចំព្រឹត្តិការណ៍ជាបន្តបន្ទាប់ផ្តោតលើការជំរុញការអប់រំតាមបែបឌីជីថល ដូចជា ពិព័រណ៍ស្ទែមប្រចាំឆ្នាំ សន្និសីទស្តីពីយុវជននិងបច្ចេកវិទ្យា ការដាក់ឱ្យដំណើរការសាលារៀនជំនាន់ថ្មី ការប្រកួតស្នាដៃ និងការសរសេរកូដ។ រាជធានី-ខេត្តដែលបានអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈមាន២៥, កម្មវិធីក្រោយអក្ខរកម្មមាន១៥, កម្មវិធីចូលរៀនឡើងវិញមាន២១, កម្មវិធីបង្កើនប្រាក់ចំណូលនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍មាន២៥ កម្មវិធីសមមូលបឋមសិក្សាមាន២៤ និងកម្មវិធីបំពេញវិជ្ជាមាន១៨។

**២៦**-ក្នុងដំណាក់កាលនៃការរីករាលដាលជំងឺកូវីដ-១៩ រាជរដ្ឋាភិបាល នៅតែបន្តបើកដំណើរការការរៀននិងបង្រៀនតាមប្រព័ន្ធអនឡាញ នៅគ្រប់កម្រិតសិក្សាចាប់ពីមត្តេយ្យរហូតដល់មធ្យមសិក្សាតាមទម្រង់ផ្សេងៗ

រួមមាន វេបសាយក្រសួងអប់រំ យុវជន និងកីឡា, កម្មវិធី YouTube និងកម្មវិធីសិក្សាពីចម្ងាយតាមប្រព័ន្ធបច្ចេកវិទ្យាជាច្រើនទៀត (Zoom, Microsoft Team, Telegram, Facebook, Messenger)។ ក្រសួងអប់រំ យុវជន និងកីឡាក៏បានសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការផ្សាយផ្ទាល់ការបង្រៀនតាមកញ្ចក់ទូរទស្សន៍ និងតាមវិទ្យុនានា តាមលទ្ធភាពនិងការពេញចិត្តពីសាលានីមួយៗ។ បន្ថែមពីនេះ ក្នុងខែមេសា ឆ្នាំ២០២១ ក្រសួងបានបង្កើតជាវេទិកាអប់រំពីចម្ងាយសម្រាប់ជួយដល់ការសិក្សារបស់សិស្សតាមប្រព័ន្ធអនឡាញ ដោយមានការគាំទ្រពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងបានបង្កើតកម្មវិធីគិតគូរកូន (Kit Kou Kon) ដើម្បីសម្រួលដល់ការសិក្សារបស់កុមារ និងផ្តល់ព័ត៌មានដែលមានប្រយោជន៍ដល់មាតាបិតា។ ក្រសួងក៏បានធ្វើការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានការគាំទ្រដោយអង្គការយូណេស្កូក្នុងការផ្តល់កម្មវិធី BEEP សម្រាប់ផ្តល់ជាធនធានបន្ថែមដល់ការសិក្សារបស់សិស្សនៅមធ្យមសិក្សាបឋមភូមិផងដែរ។ នៅដើមឆ្នាំ២០២១ រាជរដ្ឋាភិបាល បានអនុញ្ញាតឱ្យប្រើប្រព័ន្ធបច្ចេកវិទ្យាសុសវែរ (Software System) ពីរប្រភេទ សម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិត គឺ Primero and OSCaR ដើម្បីជួយដល់ការសិក្សារបស់កុមារ សិស្ស និងនិស្សិត។

## ១១-កំណែទម្រង់ដីធ្លី

(អនុសាសន៍លេខ ២០-២៣, ៤៩, ១៣០, ១៣១ និង ១៤៨)

**២៧**-គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញបណ្ណកម្មសិទ្ធិដីបានចំនួន ៧ ១៦៣ ៧៦៤បណ្ណ ក្នុងនោះបានបញ្ចប់ដំហ៊ានទី១ ចំនួន ៧លានក្បាលដី ស្មើនឹង១០០% និងបានចាប់ផ្តើមដំហ៊ានទី២ បានចំនួន ១៦៣ ៧៦៤ក្បាលដី ស្មើនឹង ៣,២៨%, បង្កើតស្ថានីយវាស់វែងដីជាអចិន្ត្រៃយ៍ចំនួន ៦៥ស្ថានីយ នៅតាមរាជធានី-ខេត្តទូទាំងប្រទេស។ ទន្ទឹមនេះ ក្រសួងក៏បានខិតខំដោះស្រាយវិវាទដីធ្លីគ្រប់រូបភាពបានសរុបចំនួន ១២ ៦៧៦ករណី និងកំពុងដោះស្រាយចំនួន ២ ៦៣៦ករណី។

**២៨**-ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងផ្តល់បណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ រាជរដ្ឋាភិបាល ក៏បានដាក់ចេញនូវគោលនយោបាយ ដូចជា (១). គោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ចដល់ប្រជាពលរដ្ឋ ដែលខ្វះដីលំនៅឋាន ដោយសម្រេចផ្តល់ដីសរុបទំហំ ១ ៣៥៦ ៧៥២,១៤ហិកតា ជូនប្រជាពលរដ្ឋសរុប ៤៨៧ ៤៥៧ គ្រួសារ និងសាងសង់ផ្ទះជូនប្រជាពលរដ្ឋសរុបចំនួន ៨ ១៤១ខ្នង។ (២). គោលនយោបាយស្តីពីការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច ដោយបានចេញបណ្ណកម្មសិទ្ធិដីសមូហភាពចំនួន ៤២ សហគមន៍ ស្មើនឹង ១ ១០៥បណ្ណ ដីទំហំ ៤១ ៥៣៨,៨២ហិកតា សម្រាប់ ៤ ១៥៩ គ្រួសារ និងបានធ្វើការកែទម្រង់បែបបទ និងនីតិវិធីនៃការស្នើសុំចុះបញ្ជីដីសមូហភាពឱ្យកាន់តែងាយស្រួលនិងឆាប់រហ័ស ដើម្បីឆ្លើយតបនឹងតម្រូវការស្នើសុំរបស់ជនជាតិដើមភាគតិច។

**២៩**-ដើម្បីសម្រេចបានសមភាពយេនឌ័រក្នុងវិស័យដីធ្លី និងការទទួលបាននូវអត្ថប្រយោជន៍ដោយសមធម៌រវាងស្ត្រីនិងបុរសក្នុងវិស័យដីធ្លី រាជរដ្ឋាភិបាល បានដាក់ចេញនូវគោលការណ៍និងសកម្មភាពដែលត្រូវប្រកាន់យកគឺ៖ (១). រាល់សកម្មភាព ឬកម្មវិធីក្នុងវិស័យដីធ្លី ត្រូវធានាថា ស្ត្រីនឹងទទួលបាននូវអត្ថប្រយោជន៍ដែលកើតចេញពីកម្មវិធី ឬសកម្មភាពទាំងនោះដោយស្មើភាព។ (២). ស្ត្រីនិងបុរស ត្រូវទទួលបាននូវព័ត៌មានដូចគ្នាអំពីគោលនយោបាយនិងច្បាប់ពាក់ព័ន្ធនឹងវិស័យដីធ្លី។ (៣). ការចុះបញ្ជីដីធ្លី ឬការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ត្រូវកំណត់ថា ជាទ្រព្យរួមរបស់ប្តីប្រពន្ធ ឬជាទ្រព្យដោយឡែករបស់ប្តី ឬរបស់ប្រពន្ធ និងត្រូវធ្វើឡើងដោយមានការចូលរួមពីស្ត្រីដោយផ្អែកលើទិដ្ឋភាពច្បាប់និងសង្គម។ (៤). ស្ត្រីជាមេគ្រួសារដែលមានបណ្ណកម្មសិទ្ធិដីធ្លី អាចយកកម្មសិទ្ធិនោះទៅដាក់ប្រាតិភោគបាន។ (៥). ស្ត្រីនិងបុរស ត្រូវទទួលបាននូវកាលានុវត្តភាព

ដូចគ្នា ក្នុងការចូលរួមផ្តល់យោបល់ក្នុងការអនុវត្ត ការអភិវឌ្ឍ ការទទួលផលដោយសមធម៌ បរិយាបន្ន និង តម្លាភាពលើវិស័យដីធ្លី។ (៦). ការលើកទឹកចិត្តឱ្យមានតំណាងជាស្ត្រីនៅគ្រប់គណៈកម្មការផ្សេងៗក្នុងវិស័យ ដីធ្លី និងក្នុងតួនាទីជាអ្នកដឹកនាំនៅគ្រប់លំដាប់ថ្នាក់ត្រូវជំរុញជាជំហានៗ។ (៧). ការពង្រឹងសមត្ថភាពអាជ្ញាធរ គ្រប់លំដាប់ថ្នាក់ និងផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងជាទូទៅពិសេសសម្រាប់ស្ត្រី។ (៨). ការរៀបចំផែនការ រៀបចំដែនដី ប្លង់គោលប្រើប្រាស់ដីធ្លី ផែនការប្រើប្រាស់ដី ផែនការអភិវឌ្ឍន៍នានា ត្រូវមានការចូលរួមពីគ្រប់ អ្នកពាក់ព័ន្ធជាពិសេសប្រជាពលរដ្ឋទាំងពីរភេទ។ (៩). ក្នុងដំណើរការបែងចែកដីធ្លី តាមរយៈការអនុវត្តកម្មវិធី សម្បទានដីសង្គមកិច្ច ឬការបែងចែកដីក្នុងគោលដៅកាត់បន្ថយភាពក្រីក្រជារូបភាពប្រទានកម្ម និងការតាំង ទីលំនៅថ្មីត្រូវធ្វើឡើងដោយសមធម៌ និងការលើកកម្ពស់សមភាពរវាងស្ត្រីនិងបុរស និង (១០). ផែនការ យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យដីធ្លីសម្រាប់រយៈពេលខ្លី មធ្យម និងវែង ត្រូវរួមបញ្ចូលនូវយុទ្ធសាស្ត្រ អភិវឌ្ឍន៍សមត្ថភាព។ ផែនការនេះ ត្រូវមានការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តពីសំណាក់ ក្រសួង/ស្ថាប័នពាក់ព័ន្ធ។

## ១២-សមភាពយេនឌ័រ និងការរើសអើងផ្លូវភេទ

(អនុសាសន៍លេខ ៤៥, ៤៦, ៥០, ៥៣, ៥៤ និង ១៧៣-១៧៩)

**៣០**-រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ (២០១៩-២០២៣) ដើម្បី «កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព» បានកំណត់ «ការពង្រឹងសមភាពយេនឌ័រ» ដោយសំដៅលើ ការពង្រឹងតួនាទីស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ ក្នុងនោះ បានបន្តលើកកម្ពស់សិទ្ធិ ឋានៈ តួនាទី របស់ស្ត្រី តាមរយៈការបង្កើនការវិនិយោគលើសមភាពយេនឌ័រនៅក្នុងគោលនយោបាយ ផែនការអនុវត្តន៍គ្រប់ ផ្នែក គ្រប់វិស័យ រួមមានៈ ការបង្កើនសមាមាត្រ និងការពង្រឹងសមត្ថភាពស្ត្រីក្នុងជួរថ្នាក់ដឹកនាំ លើកកម្ពស់ សហគ្រិនភាពរបស់ស្ត្រី និងសេដ្ឋកិច្ចគ្រួសារ សុខភាពស្ត្រី និងការអប់រំ ទប់ស្កាត់ការជួញដូរ ការរំលោភ បំពានផ្លូវភេទ និងអំពើហិង្សាលើស្ត្រី និងកុមារ បង្កើនការយល់ដឹងដល់ស្ត្រីអំពីភាពធន់ទៅនឹងការប្រែប្រួល អាកាសធាតុ និងលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរ។

**៣១**-អនុលោមតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤នេះ រាជរដ្ឋាភិបាលបន្តលើកស្ទួយស្ថានភាពស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ ដោយផ្តោតលើការពន្លឿនវឌ្ឍនភាពឆ្ពោះទៅសម្រេចបានសមភាព យេនឌ័រ និងការលើកកម្ពស់ភាពអង់អាចរបស់ស្ត្រី រួមទាំងការលុបបំបាត់គ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រីនិង ក្មេងស្រី ដើម្បីបង្កើននូវលក្ខខណ្ឌសមធម៌ និងការទទួលស្គាល់សមភាពរវាងស្ត្រីនិងបុរសក្នុងគ្រប់ទិដ្ឋភាព ព្រមទាំងសិទ្ធិក្នុងការចូលរួមចំណែកដោយស្មើភាព និងជាដៃគូមិនអាចខ្វះបានជាមួយបុរសក្នុងការអភិវឌ្ឍ ប្រទេសជាតិ។

**៣២**-ជាក់ស្តែងរាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយសំខាន់ៗ រួមមាន ផែនការសកម្មភាព ជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៣ (២០១៩-២០២៣) និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ (២០១៩-២០២៣) សំដៅលើកកម្ពស់សិទ្ធិស្ត្រី និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ នឹងបានដាក់ចេញនូវវិធានការដាក់លាក់ចំនួន៤ រួមមាន (១). ការបង្កើនការវិនិយោគទៅលើសមភាពយេនឌ័រ, (២). ការធានានូវការការពារសិទ្ធិស្ត្រី ព្រមទាំងការចូលរួមពេញលេញ និងស្មើភាពរបស់ស្ត្រីក្នុងការធ្វើសេចក្តី សម្រេចនៅគ្រប់កម្រិត, (៣). ការពង្រឹងយន្តការគណនេយ្យភាពសម្រាប់សមភាពយេនឌ័រ និង(៤). បន្តការ លើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងសេដ្ឋកិច្ច និងបរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី ដែលធ្វើឱ្យមានការកើនឡើង

ជាបណ្ដើរៗនូវសមាមាត្រស្ត្រីជាអ្នកដឹកនាំទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ១៣-អំពើហិង្សាលើស្ត្រី និងកុមារ

(អនុសាសន៍លេខ ១៣២, ១៨០ និង ១៨២-១៨៦)

**៣៣**-ក្រសួងកិច្ចការនារី បានរៀបចំនិងដឹកនាំយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងកែប្រែឥរិយាបថសង្គម កៀរគរការចូលរួមលើកទឹកចិត្តឱ្យមានការពង្រឹងភាពអង់អាចរបស់ស្ត្រី និងការចូលរួមរបស់បុរសក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារទូទាំងប្រទេសតាមរយៈប្រព័ន្ធព័ត៌មានសង្គម និងសកម្មភាពសង្គមជាច្រើន។ ក្នុងការអនុវត្តផែនការសកម្មភាព ជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ ក្រសួង/ស្ថាប័នពាក់ព័ន្ធបានដាក់ចេញនូវកម្មវិធីការងារតាមវិស័យរៀងៗខ្លួន។ ផ្អែកលើលទ្ធផលនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០២១-២០២២ បានបង្ហាញថា អំពើហិង្សាពីដៃគូស្និទ្ធស្នាលបានថយចុះពី២៩% ក្នុងឆ្នាំ២០១៤ មកនៅត្រឹម២១%ក្នុងឆ្នាំ២០២១។

**៣៤**-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី បានផ្ដល់សេវាជំនួយផ្នែកច្បាប់ដោយមិនយកកម្រៃដល់ស្ត្រីនិងក្មេងស្រីក្រីក្ររងគ្រោះដោយអំពើហិង្សា លើសេវាចំនួន ២ គឺ សេវាអន្តរាគមន៍របស់មន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌របស់ក្រសួង/មន្ទីរកិច្ចការនារីនៅទូទាំងប្រទេស និងសេវាការពារក្ដីនៅតាមសាលាជំនុំជម្រះក្ដីគ្រប់ជាន់ថ្នាក់។ ព្រមជាមួយនេះ ក្រុមមេធាវីស្ម័គ្រចិត្តសម្ដេចតេជោសែន, គ.ស.ម.ក., និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានជួយផ្ដល់សេវាផ្លូវច្បាប់ដោយឥតគិតថ្លៃដល់ស្ត្រី និងក្មេងស្រីក្រីក្ររងគ្រោះផងដែរ។ ជាក់ស្ដែងក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ គណៈមេធាវីបានធ្វើការពិគ្រោះយោបល់ផ្លូវច្បាប់ដោយមិនយកកម្រៃសរុបបាន ២ ៣៧៦ករណី និងបានចាត់តាំងមេធាវីការពារក្ដីជូនជនក្រីក្របានចំនួន ២៣ ៦៥៦ករណី មានកូនក្ដីសរុប ៣៦ ៦១០នាក់ (ស្ត្រី និងអនីតិជន ១២ ៣៥២នាក់)។

**៣៥**-ក្រសួងអប់រំ យុវជន និងកីឡា បានដាក់បញ្ចូលការអប់រំអំពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ សិទ្ធិបន្តពូជ និងសិទ្ធិផ្លូវភេទទៅក្នុងកម្មវិធីសិក្សារបស់ជាតិលើមុខវិជ្ជាអប់រំសុខភាពពីថ្នាក់ទី៥ ដល់ទី១២ និងមានមេរៀនអំពីការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅក្នុងកម្មវិធីសិក្សាបំណិនជីវិតសម្រាប់ថ្នាក់មធ្យមសិក្សាបឋមភូមិ។ ទន្ទឹមនេះ រោងចក្រនិងសហគ្រាសចំនួន ៥៦ កំពុងអនុវត្តគោលនយោបាយស្ដីពីការទប់ស្កាត់ ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ។

**៣៦**-រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវផែនការសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ដែលមានយុទ្ធសាស្ត្រចំនួន ៧ របស់សម្ព័ន្ធសកល (INSPIRE: (១). ការអនុវត្ត និងការពង្រឹងប្រសិទ្ធភាពច្បាប់, (២). ស្តង់ដារ និងគុណតម្លៃ, (៣). បរិយាកាសមានសុវត្ថិភាព, (៤). ជំនួយសម្រាប់ឪពុកម្ដាយ, (៥). ប្រាក់ ចំណូល និងពង្រឹងសេដ្ឋកិច្ច, (៦). សេវាឆ្លើយតបនិងគាំទ្រ និង (៧). ការអប់រំ និងបំណិនជីវិត) សម្រាប់បញ្ចប់អំពើហិង្សាលើកុមារ ស្របតាមការឆ្លើយតបរបស់កម្ពុជា និងរបស់អាស៊ានចំពោះអំពើហិង្សាលើកុមារ។ បន្ថែម ពីនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់បញ្ចូលចំណុចដៅ ១៦.២ នៃគោលដៅទី១៦ ទៅក្នុងគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពកម្ពុជា (CSDGs) ស្ដីពីការបញ្ចប់អំពើហិង្សាលើកុមារ។

**៣៧**-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអនុវត្តយុទ្ធសាស្ត្រ Cambodia PROTECT សម្រាប់លើកកម្ពស់ការយល់ដឹង និងការផ្លាស់ប្ដូរការប្រព្រឹត្ត តាមរយៈយុទ្ធនាការ «គ្រួសាររឹងមាំ» ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារ។ ទន្ទឹមគ្នានេះ ក្នុងឆ្នាំ២០១៩ ក្រសួងបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល ចូលជាសមាជិកនៃប្រទេសដៃគូសកល ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ

(Pathfinding country to end violence against children)។ គិតពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ មានអំពើហិង្សាក្នុងគ្រួសារបានកើតឡើងចំនួន ៧៨៩ករណី ដោះស្រាយបានចំនួន ៧៨០ករណី (ក្នុងនោះដោះស្រាយតាមប្រព័ន្ធតុលាការបានចំនួន ៣៩៩ករណី និងក្រៅប្រព័ន្ធតុលាការបានចំនួន ៣៨១ករណី)។ ក្រសួងកិច្ចការនារី បានផ្តល់សេវាជួយជនរងគ្រោះគិតពីឆ្នាំ២០១៩ ដល់ ឆ្នាំ២០២១ មានអំពើហិង្សាក្នុងគ្រួសារបានកើតឡើងទាំងថ្នាក់ជាតិ និងក្រោមជាតិមានចំនួន ៧៨៩ករណី ដោះស្រាយបានចំនួន ៧៨០ករណី (ក្នុងនោះដោះស្រាយតាមប្រព័ន្ធតុលាការបានចំនួន ៣៩៩ករណី និងក្រៅប្រព័ន្ធតុលាការបានចំនួន ៣៨១ករណី)។

**៣៨**-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យប្រើប្រាស់គោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារកាលពីខែឧសភា ឆ្នាំ២០២០។ គោលនយោបាយជាតិនេះបានបន្សុីយន្តការដែលមានស្រាប់ និងបន្តអនុវត្តឱ្យមានលក្ខណៈជាប្រព័ន្ធ ក្នុងការផ្តល់សេវាប្រកបដោយសង្គតិភាពសម្រាប់កុមារនិងគ្រួសារកុមារ ដើម្បីធានាថា បញ្ហាកុមារត្រូវបានដាក់បញ្ចូលទៅក្នុងគ្រប់វិស័យពាក់ព័ន្ធ។ គោលនយោបាយជាតិនេះ បានកំណត់នូវសសរស្តម្ភចំនួន ៣ គឺ៖ ការបង្ការនិងទប់ស្កាត់, ការអន្តរាគមន៍ និងការផ្តល់សេវាឆ្លើយតប ដែលសសរស្តម្ភនីមួយៗផ្តោតលើមុំ ៤ គឺ៖ ប្រព័ន្ធអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាល, ប្រព័ន្ធសុខុមាលភាពកុមារ, ប្រព័ន្ធយុត្តិធម៌ និងប្រព័ន្ធសុខាភិបាល។

**៣៩**-ដើម្បីជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ២០១៩-២០២៩ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានរៀបចំផែនការអនុវត្ត រួមមាន៖ (១). ផែនការសកម្មភាព ២០២១-២០២៥, (២). ផែនការអភិវឌ្ឍន៍ធនធានមនុស្សនិងថវិកា និង (៣). ផែនការត្រួតពិនិត្យនិងវាយតម្លៃ។ ទន្ទឹមនឹងនេះក្រុមប្រឹក្សាជាតិដើម្បីកុមារ ក៏បានរៀបចំផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (ឆ្នាំ២០២១-២០២៥) ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការក្នុងខែកក្កដា ឆ្នាំ២០២១។

## ១៤-អាពាហ៍ពិពាហ៍របស់ស្ត្រី និងកុមារ

(អនុសាសន៍លេខ ១៧២ និង ១៩០)

**៤០**-មាត្រា៩៥០ នៃក្រមរដ្ឋប្បវេណី ចែងថា «នារីពុំអាចរៀបអាពាហ៍ពិពាហ៍ជាថ្មីទៀតបានឡើយក្នុងរយៈពេល១២០ថ្ងៃ ក្រោយការលែងលះ។» បទប្បញ្ញត្តិនេះ មិនមែនជាការហាមឃាត់ដែលមានលក្ខណៈរើសអើងចំពោះការរៀបអាពាហ៍ពិពាហ៍ម្តងទៀតរបស់ស្ត្រី ក្នុងរយៈពេល១២០ថ្ងៃបន្ទាប់ពីការលែងលះនោះទេ។ ប៉ុន្តែបទប្បញ្ញត្តិនេះ មានគោលបំណងការពារផលប្រយោជន៍របស់នារី ឬបុរស ឬទារកក្នុងផ្ទៃ ក្នុងករណីនារីនោះមានផ្ទៃពោះ ដូចកថាខណ្ឌទី២ នៃមាត្រា៩៥០ ដដែលនេះ បានចែងថា៖«បញ្ញត្តិខាងលើនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលនារីមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍ត្រូវបានរំលាយ ឬលុបចោលហើយបានសម្រាលកូនឬចំពោះករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត។»

**៤១**-មាត្រា៩៤៨ នៃក្រមរដ្ឋប្បវេណីចែងថា៖«បុរសនិងនារីដែលមិនទាន់ដល់នីតិភាពមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ។»

**៤២**-មាត្រា១៧ នៃក្រមរដ្ឋប្បវេណី បានកំណត់ថា៖«អនីតិជន សំដៅលើជនដែលមានអាយុក្រោម១៨ឆ្នាំ។» មាត្រា២១ និង ២២ នៃក្រមនេះដែរ បានកំណត់ថា៖«(១). ក្នុងករណីដែលអនីតិជនដែលដល់អាយុ ១៦ឆ្នាំ

ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបាន តាមពាក្យសុំរបស់អនីតិជននោះ។ (២). អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាពដោយមិនចាំបាច់មានការប្រកាសពីតុលាការ។ (៣). អនីតិជនដែលទទួលបានអត្តាធីនភាព ត្រូវបានចាត់ទុកថា បានដល់នីតិភាព។»

**៤៣**-មាត្រា ៩៥៣ នៃក្រមរដ្ឋប្បវេណី បានកំណត់ថា៖«ក្នុងករណីដែលភាគីម្ខាងក្នុងចំណោមភាគីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាអនីតិជន ចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលទាំងសងខាង ឬតែម្ខាងក៏បានដែរ។ ក្នុងករណីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលមិនយល់ព្រម អនីតិជនដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ អាចទាមទារទៅតុលាការឱ្យសម្រេចសេចក្ដីជំនួសការយល់ព្រមនោះបាន។»

**៤៤**-ក្រសួងកិច្ចការនារី បានផ្តល់ការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្តរតនគិរីក្នុងការអនុវត្តសាកល្បងកម្មវិធីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់ ដោយបានផ្តល់ការគាំទ្របច្ចេកទេសក្រោយពេលទទួលបានអត្តាធីនភាពពីតុលាការ អនីតិជននោះចាត់ទុកថាដល់នីតិភាពហើយ គឺអាចរៀបការបាន។ ក្រសួងបានដាក់ឱ្យអនុវត្តនូវផែនការសកម្មភាពស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់ខេត្តរតនគិរី (២០១៧-២០២១)។ ផែនការសកម្មភាពនេះ ត្រូវបានរដ្ឋបាលខេត្តរតនគិរីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ខេត្ត និងបានបែងចែកថវិកាសម្រាប់អនុវត្តសកម្មភាពទាក់ទងនឹងការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់។

## ១៥-ពលកម្មកុមារ

(អនុសាសន៍លេខ ១៩២ និង១៩៣)

**៤៥**-រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានបន្តពង្រឹងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (២០១៦-២០២៥) ដោយផ្តោតលើមុខព្រួញចំនួន ៤ គឺ៖ (១). ពង្រឹងការតាមដាននិងអនុវត្តគោលនយោបាយស្តីពីពលកម្មកុមារ ដូចជា អនុសញ្ញាអន្តរជាតិខាងការងារដែលកម្ពុជាបានផ្តល់សច្ចាប័ន, ជំរុញការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ៨.៧ ស្តីពីការបញ្ចប់ពលកម្មកុមារ ពលកម្មដោយបង្ខំ ទាសភាពសម័យទំនើប និងការជួញដូរមនុស្ស, តាមដានការអនុវត្តច្បាប់ស្តីពីការងារនិងប្រកាសចំនួន ១៣ ពាក់ព័ន្ធនឹងពលកម្មកុមារ។ (២). ពង្រឹងយន្តការ និងកសាងសមត្ថភាពមន្ត្រីអធិការកិច្ចការងារ ដូចជា យន្តការនៃគណៈកម្មាធិការប្រឆាំងពលកម្មកុមារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស និងគណៈកម្មការគាំពារនិងអភិវឌ្ឍន៍កុមារតូច។ ចាប់ពីឆ្នាំ២០១៩ ដល់ខែតុលា ឆ្នាំ២០២៣ វគ្គបណ្តុះបណ្តាលចំនួន ១៧លើក ត្រូវបានរៀបចំឡើងពាក់ព័ន្ធនឹងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងមានអ្នកចូលរួមសរុប ២ ៣១៦នាក់ (ស្រី ៣៧៨នាក់) មានទាំងមន្ត្រីអធិការកិច្ចការងារផងដែរ។ (៣). កិច្ចអន្តរាគមន៍ស្នូល និងការអនុវត្តច្បាប់ ដូចជា ចុះធ្វើអធិការកិច្ចការងារដោយមិនជូនដំណឹងនៅគ្រប់មុខរបរ ដែលជាវិស័យអាទិភាពនិងមានហានិភ័យខ្ពស់ ចុះធ្វើអធិការកិច្ចការងារតាមរោងចក្រ សហគ្រាសគ្រឹះស្ថាន ដែលបានស្នើសុំប្រើប្រាស់កម្មករនិយោជិតវ័យក្មេង និងកិច្ចអន្តរាគមន៍ស្នូលក្នុងការទប់ស្កាត់ ការពារ និងបន្ត ការគាំពារកុមារ។ ជាក់ស្តែង ចាប់ពីឆ្នាំ២០១៩ ដល់ខែតុលា ឆ្នាំ២០២៣ កុមាររងាយរងគ្រោះចំនួន ១ ៥៥០នាក់ ត្រូវបានទប់ស្កាត់និងទទួលការអប់រំបណ្តុះបណ្តាលជំនាញ និងបង្កើតមុខរបរបំពេញបន្ថែមសម្រាប់គ្រួសារកុមារ។ យោងតាមការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច (ឆ្នាំ២០១២-២០១៩/២០) បានរកឃើញ

ថា ភាគរយកុមារចូលរួមធ្វើការបានថយចុះពី២៤%ក្នុងឆ្នាំ២០១២ មកត្រឹម១៧%ក្នុងឆ្នាំ២០២១។ ម្យ៉ាងទៀត យោងតាមរបាយការណ៍របស់គម្រោងរោងចក្រកាន់តែប្រសើរ នៃអង្គការអន្តរជាតិខាងការងារ (ILO-BFC) ករណីពលកម្មកុមារនៅតាមរោងចក្រ សហគ្រាស ក្នុងវិស័យវាយនភណ្ឌកាត់ដេរ ស្បែកជើង កាបូប និងផលិតផលិតផលធ្វើដំណើរបានថយចុះពី១ករណីនៅឆ្នាំ២០១៩ មកត្រឹមសូន្យករណីនៅឆ្នាំ២០២២។ (៤). ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យ ដែលមានហានិភ័យខ្ពស់ ដូចជា វាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើងនិងផលិតផលិតផលធ្វើដំណើរនិងកាបូប សិប្បកម្មផលិតឥដ្ឋ ចម្ការដំឡូងមី និងចម្ការអំពៅ។ គិតចាប់ពីឆ្នាំ២០១៩ ដល់ខែតុលា ឆ្នាំ២០២៣ យុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារចំនួន ៥៤៤លើក ត្រូវបានរៀបចំឡើង ដោយមានការចូលរួមពីនិយោជក កម្មករនិយោជិត ឪពុកម្តាយ អាណាព្យាបាល និងកុមារចំនួន ១៤ ១៣៥នាក់ (ស្រី ៦ ០៧៣នាក់) និងបានរៀបចំផលិតវីដេអូឃ្លីបខ្លីៗសម្រាប់ផ្សព្វផ្សាយអប់រំ ហើយទិវាពិភពលោកប្រឆាំងពលកម្មកុមារត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំនៅទូទាំងប្រទេស។

## ១៦-ការចុះបញ្ជីកំណើត

(អនុសាសន៍លេខ ១៣៥ និង ១៣៦)

**៤៦**-ផ្អែកលើច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨ កូនដែលកើតពីឪពុក និងម្តាយជាជនបរទេស អាចទទួលបានសញ្ជាតិខ្មែរ លុះត្រាតែឪពុកនិងម្តាយនោះកើតនិងរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ឬកូនដែលកើតពីឪពុកម្តាយមិនស្គាល់ ឬកូនទើបនឹងកើតដែលគេរើសបានក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកចំពោះការសុំកូនពេញលេញដោយសហព័ទ្ធពលរដ្ឋខ្មែរ ត្រូវទទួលបានសញ្ជាតិខ្មែរ នៅពេលដែលការសុំកូនពេញលេញត្រូវបានបង្កើតឡើងស្របតាមច្បាប់ជាធរមាន។

**៤៧**-រាជរដ្ឋាភិបាលកម្ពុជា បានចេញអនុក្រឹត្យលេខ ១០៣ ក្នុងឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន ដើម្បីផ្តល់ការចុះបញ្ជីកំណើតដល់ពលរដ្ឋខ្មែរគ្រប់រូប និងទារកដែលកើតពីឪពុកម្តាយជាជនបរទេសដែលរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ ពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិធ្វើការស្នើសុំចុះបញ្ជីកំណើតនៅតាមឃុំ-សង្កាត់ នៃលំនៅឋានរបស់ខ្លួន ឬរបស់ឪពុកម្តាយ។ ការចុះបញ្ជីកំណើតត្រូវបានអនុវត្តដោយស្មើភាព តម្លាភាព គ្មានការរើសអើង និងមិនតម្រូវឱ្យបង់ប្រាក់ឡើយ។ ជារួម ការទទួលបានសញ្ជាតិខ្មែរត្រូវតែអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ១៧-យុត្តិធម៌អនីតិជន

(អនុសាសន៍លេខ ១៩៤)

**៤៨**-ផ្អែកលើច្បាប់ស្តីពីយុត្តិធម៌អនីតិជន រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរយៈពេល៣ឆ្នាំ (២០១៨-២០២០) ដោយផ្តោតសំខាន់លើការធ្វើឱ្យមានការយល់ដឹងពីផលប្រយោជន៍នៃការអនុវត្តនូវវិធានការបង្វែរ និងវិធានការផ្សេងទៀតក្រៅពីការឃុំខ្លួនអនីតិជន ដោយបានបង្កើតក្រុមការងារអន្តរក្រសួង ដែលមានសមាសភាពមកពីក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងសាលាឧទ្ធរណ៍។ ក្រុមការងារនេះ បានសហការជាមួយអង្គការយូនីសេហ្វ បាននិងកំពុងសិក្សាពីលទ្ធភាពក្នុងការជំរុញការអនុវត្តទោសជំនួសសម្រាប់បទល្មើសស្រាលៗចំពោះអនីតិជន។

**៤៩**-រាជរដ្ឋាភិបាលបានចេញគោលការណ៍ណែនាំកាលពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពី៖ (១). នីតិវិធីយុត្តិធម៌អនីតិជនប្រៀបធៀបនឹងនីតិវិធីព្រហ្មទណ្ឌសាមញ្ញ, (២). ប្រព័ន្ធយុត្តិធម៌ទាក់ទងនឹងកុមារនៅក្នុង

ដំណើរការនីតិវិធីតុលាការក្នុងប្រទេសកម្ពុជា និង (៣). ការបង្វែរអនីតិជនទំនាស់នឹងច្បាប់។ ជាមួយគ្នានេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចេញប្រកាសលេខ ១២៨ ឆ្នាំ២០២៣ ស្ដីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីប្រតិបត្តិបទដ្ឋានសម្រាប់គ្រប់គ្រងមណ្ឌលយុវនីតិសម្បទា។ នៅដើមឆ្នាំ២០២៣ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអនុវត្តសាកល្បងទម្រង់ផែនការបង្វែរអនីតិជនទំនាស់នឹងច្បាប់ និងទម្រង់របាយការណ៍ស្ដីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនទំនាស់នឹងច្បាប់។ ក្រសួងក៏បានបង្កើតមណ្ឌលយុវនីតិសម្បទា និងបានសម្ពោធដាក់ឱ្យប្រើប្រាស់នៅចុងឆ្នាំ ២០២១ ដែលមានលទ្ធភាពទទួលអនីតិជនមកស្នាក់នៅប្រមាណជាង ១ ០០០នាក់។ បច្ចុប្បន្ន បាននិងកំពុងតាក់ តែងផែនការ វិធានការ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា ដើម្បីផ្ទេរការគ្រប់គ្រងជនជាប់ឃុំទាំងអស់ជាអនីតិជន ពីក្រសួងមហាផ្ទៃ ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្របតាមច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ទៅដាក់នៅក្នុងមណ្ឌលយុវនីតិសម្បទា។ ជាមួយគ្នានេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាននិងកំពុងរៀបចំច្បាប់ស្ដីពីកិច្ចការពារកុមារ ក្នុងគោលបំណងដើម្បីធានាកិច្ចការពារកុមារស្របតាមតម្រូវការចាំបាច់នៃស្ថានភាពកុមារនៅកម្ពុជា។

**១៨-សិទ្ធិជនមានពិការភាព**

(អនុសាសន៍លេខ ១៨១ និង ១៩៥-១៩៨)

**៥០**-រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព ២០១៩-២០២៣ ដើម្បីឆ្លើយតបទៅនឹងការលើកកម្ពស់សិទ្ធិជនពិការ, អនុសញ្ញាស្ដីពីសិទ្ធិជនមានពិការភាព និងយុទ្ធសាស្ត្រអ៊ីឈាន់ «ធ្វើសិទ្ធិក្លាយជាការពិត» ក៏ដូចជាគោលនយោបាយអភិវឌ្ឍន៍ផ្សេងៗ។ ផែនការយុទ្ធសាស្ត្រនេះ មានគោលបំណង៖ (១). ធ្វើឱ្យគុណភាពជីវិតជនមានពិការភាព និងស្ថានភាពគ្រួសារមានភាពប្រសើរឡើង គោរពសេចក្ដីថ្លៃថ្នូរពីកំណើតនិងការរស់នៅដោយឯករាជ្យ ព្រមទាំងសុខុមាលភាពពេញលេញ និង (២). លើកកម្ពស់ភាពស្មើគ្នាចំពោះមុខច្បាប់ ទទួលបានសេវាយុត្តិធម៌ ចាកផុតពីអំពើទារុណកម្ម ការរំលោភបំពាន ការកេងប្រវ័ញ្ច អំពើហិង្សា និងទទួលបានដំណោះស្រាយនៅគ្រាមានអាសន្ន ព្រមទាំងលើកស្ទួយសមភាពស្ត្រី និងកុមារមានពិការភាព ព្រមទាំងជនមានពិការភាពគ្រប់ប្រភេទ។ ផែនការយុទ្ធសាស្ត្រនេះ ក៏បានដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រចំនួន ៩ រួមមាន៖ (១). បង្កើនការងារ និងសន្តិសុខសេដ្ឋកិច្ច, (២). បង្កើនលទ្ធភាពទទួលបានសេវាសុខភាព និងស្ដារលទ្ធភាពពលកម្ម, (៣). លទ្ធភាពទទួលបានការអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ, (៤). ការបង្កលក្ខណៈងាយស្រួល, (៥). ការចូលរួមដោយសមភាព, (៦). លទ្ធភាពទទួលបានសេវាយុត្តិធម៌ និងសិទ្ធិសេរីភាព, (៧). ធានាសមភាពយេនឌ័រ, (៨). កាត់បន្ថយហានិភ័យ និងផលប៉ះពាល់បង្កដោយគ្រោះមហន្តរាយ និង (៩). ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌជាតិនិងអន្តរជាតិ។

**៥១**-រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់លើកកម្ពស់សិទ្ធិជនមានពិការភាព ជាអាទិ៍ ជនមានពិការភាពត្រូវ បានលើកទឹកចិត្តឱ្យចូលរួមបម្រើការងារនៅតាមក្រសួង/ស្ថាប័នក្នុងអត្រាកំណត់ ២% និងវិស័យឯកជនក្នុង អត្រាកំណត់ ១%។ គិតត្រឹមឆ្នាំ២០២២ មានមន្ត្រីរាជការមានពិការភាពមានចំនួន ៣ ៧៤៨នាក់ និងក្នុងវិស័យឯកជន ដូចជា ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សណ្ឋាគារ រោងចក្រ និងកាស៊ីណូ មានជនមានពិការភាពចូលបម្រើការងារចំនួន ៥ ៨៣៩នាក់ នៅក្នុង ២៩១ គ្រឹះស្ថាន រោងចក្រ និងសហគ្រាស។

**៥២**-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អនុវត្តគម្រោងកម្មវិធីនានាជួយដល់កុមារមានពិការភាព និងជនមានពិការភាពគ្រប់ប្រភេទឱ្យ

ទទួលបាននូវសេវាសិក្សាអប់រំ និងសេវាសង្គមចាំបាច់នានា ដើម្បីឱ្យពួកគាត់អាចមានលទ្ធភាពចូលរួមគ្រប់សកម្មភាពនានារបស់សង្គមជាតិ ព្រមទាំងផ្តល់របបគោលនយោបាយចំពោះជនមានពិការភាពក្រីក្រនៅតាមសហគមន៍នៅទូទាំង ២៥រាជធានី-ខេត្ត ស្មើនឹង ៦០ក្រុង-ស្រុក-ខណ្ឌ ដែលមានជនមានពិការភាពសរុបចំនួន ១៩ ៨៧៤នាក់ ទទួលផលពីកម្មវិធីនេះ។ ក្នុងឆ្នាំ២០២៣ បណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនមានពិការភាពសរុបចំនួន ៣៥នាក់ លើមុខវិជ្ជាផ្នែកអេឡិចត្រូនិច ម៉ាស៊ីន កាត់ដេរ និងជួសជុលទូរស័ព្ទ បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងជនបង្គោលឃុំ-សង្កាត់ សរុបចំនួន ៦ ៣៤៩នាក់ ស្តីពីការអនុវត្តកម្មវិធីកំណត់អត្តសញ្ញាណជនមានពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋានជូនជនមានពិការភាពបានចំនួន ២៦០ ០០៤នាក់ និងបានផលិតបណ្ណសម្គាល់ជនមានពិការភាពបានចំនួន ២០០ ៤៥៤បណ្ណ។ ដើម្បីធានាសុខុមាលភាពជនមានពិការភាពកាន់តែប្រសើរឡើង ជាពិសេស ដើម្បីឱ្យជនមានពិការភាពទទួលបាននូវសិទ្ធិថែទាំសុខភាពដោយឥតគិតថ្លៃ រាជរដ្ឋាភិបាល បាននិងកំពុងបន្តអនុវត្តកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ផ្តល់ជាមធ្យោបាយជួយជនមានពិការភាព និងគ្រួសារក្រីក្រទាំងអស់ឱ្យទទួលបានសេវាថែទាំសុខភាព ដោយប្រើប្រាស់ថវិកាមូលនិធិសមធម៌របស់រាជរដ្ឋាភិបាល។

**៥៣**-ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់លើកកម្ពស់សិទ្ធិទទួលបានការអប់រំសម្រាប់កុមារមានពិការភាព ដូចជា៖ (១). បានបោះពុម្ពសៀវភៅអក្សរប្រេយ៍ និងសៀវភៅភាសាសញ្ញា ១ ៧៩២ក្បាល, (២). បានផ្តល់សេវាអប់រំសម្រាប់កុមារមានពិការភាព ដោយបានអនុវត្តនៅវិទ្យាល័យអប់រំពិសេសសម្រាប់សិស្សពិការភ្នែក គថ្លង់ និងពិការសតិបញ្ញា និងអូទីស្សឹម ៦កន្លែង មានសិស្ស ១ ០៩៤នាក់ ស្រី ៤១២នាក់, (៣). ផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ការហូបចុក ស្នាក់នៅ សោហ៊ុយធ្វើដំណើរដល់សិស្សពិការភ្នែក គថ្លង់ សតិបញ្ញា និងអូទីស្សឹម និងផ្តល់ថវិកាមូលនិធិសម្រាប់ដំណើរការសាលារៀនសាធារណៈដល់វិទ្យាល័យអប់រំពិសេស, (៤). បើកថ្នាក់សមាហរណកម្មគថ្លង់ ពិការភ្នែក និងសតិបញ្ញា និងអូទីស្សឹម ៤៧សាលា សិស្ស ៨០២នាក់ ស្រី ២៧២នាក់, (៥). បានបណ្តុះបណ្តាលគ្រូជំនាញពិសេសសម្រាប់បង្រៀនសិស្សពិការភ្នែក គថ្លង់ និងសតិបញ្ញា នៅវិទ្យាស្ថានជាតិអប់រំពិសេស, (៦). បានបំប៉នសមត្ថភាពស្តីពីការអប់រំបរិយាបន្ន និងការអប់រំពិសេសដល់គ្រូបង្រៀនថ្នាក់អប់រំបរិយាបន្ន ថ្នាក់សមាហរណកម្ម និងវិទ្យាល័យអប់រំពិសេស, និង (៧). រៀបចំវេទិកាថ្នាក់ជាតិស្តីពីការអប់រំ បរិយាបន្ន ។

**៥៤**-កម្មវិធីសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលអូស្ត្រាលី ស្តីពីការលើកកម្ពស់និរន្តរភាពក្នុងការផ្តល់សេវានិងសមធម៌ ហៅកាត់ថា កម្មវិធី ACCESS ដែលអនុវត្តដោយក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ បានអភិវឌ្ឍឯកសារនិងធ្វើការបណ្តុះបណ្តាលគ្រូបង្គោលស្តីពីសមភាពយេនឌ័រ និងបរិយាបន្នពិការភាពបានចំនួន ៥២វគ្គ ដោយមានអ្នកចូលរួមសរុបចំនួន ១ ៧៧៣នាក់ ក្នុងនោះមានអ្នកមានពិការភាពសរុបចំនួន ៤២០នាក់ ដែលមកពីខេត្តគោលដៅចំនួន៧។

## ១៩-សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា

(អនុសាសន៍លេខ ៤៥, ៤៧ និង ៥០-៥៥)

**៥៥**-បទប្បញ្ញត្តិប្រឆាំងការរើសអើងគ្រប់រូបភាព ត្រូវបានចែងក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាពីមាត្រា២៦៥ ដល់មាត្រា២៧០។ រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តក្នុងការប្រយុទ្ធប្រឆាំងការរើសអើងគ្រប់ប្រភេទ រួមទាំងការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ

និងពង្រីកឱ្យកាន់តែទូលំទូលាយនូវការអប់រំបុគ្គល គ្រួសារ សហគមន៍ និងសង្គម ដើម្បីឱ្យមានការទទួលស្គាល់នូវសិទ្ធិសេរីភាពអ្នកស្រឡាញ់ភេទដូចគ្នាឱ្យកាន់តែទូលំទូលាយ។

**៥៦**-ក្រសួងកិច្ចការនារី បានដាក់បញ្ចូលក្រុមស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាក្រុមងាយរងគ្រោះ ដែលជាអាទិភាពមួយនៅក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៣។ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកម្មវិធីសិក្សាអំពីការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយក្នុងសាលារៀន ដោយបញ្ចូលនូវខ្លឹមសារសមភាពយេនឌ័រ និងគោលគំនិតនិន្នាការភេទ អត្តសញ្ញាណយេនឌ័រការបង្ហាញយេនឌ័រ និងលក្ខណៈភេទស្របទៅតាមកម្រិតសិក្សា និងភាសាសម្រាប់សិស្ស។ ក្រសួង/ស្ថាប័នពាក់ព័ន្ធ បានសហការជាមួយអង្គការសង្គមស៊ីវិល សមាគម និងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ដើម្បីឱ្យពួកគេមានសិទ្ធិសេរីភាព និងសមភាពដូចបុរសនារីផ្សេងទៀតក្នុងការរស់នៅក្នុងសង្គម ជាពិសេស ការទទួលស្គាល់ពីញាតិសណ្តាន មិត្តភក្តិ ក្រុមគ្រួសារ និងសង្គម ព្រមទាំងក្នុងកន្លែងការងារទាំងសាធារណៈ និងឯកជនឱ្យកាន់តែទូលំទូលាយ។

**៥៧**-ទោះបីប្រទេសកម្ពុជាមិនទាន់មានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ទទួលស្គាល់អាពាហ៍ពិពាហ៍ និងការប្តូរអត្តសញ្ញាណយេនឌ័ររបស់អ្នកស្រឡាញ់ភេទដូចគ្នា តែកម្ពុជាក៏មិនបានហាមឃាត់ រឹតត្បិត ឬដាក់ទោសទណ្ឌចំពោះអ្នកទាំងនោះឡើយ។ ផ្ទុយទៅវិញ តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស ក្រោយពីការទទួលយកអនុសាសន៍ទាំងអស់ពាក់ព័ន្ធនឹងសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានាពេលកន្លង បានក្លាយជាសារមួយដ៏សំខាន់ជំរុញឱ្យពួកគេកាន់តែមានភាពក្លាហាន ហ៊ានចេញមុខបង្ហាញភាពជាខ្លួនឯង និងតស៊ូមតិដើម្បីសិទ្ធិសេរីភាពរបស់ក្រុមខ្លួន។ យោងតាមការវាយតម្លៃរបស់អង្គការ Rainbow Community Kampuchea Organization (ROCK) បានបង្ហាញថា ចាប់ពីឆ្នាំ២០១៩ មកស្ថានភាពសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ត្រូវបានមហាជនឱ្យតម្លៃ និងគោរព ព្រមទាំងមានការទទួលស្គាល់ពីគ្រួសារ និងសង្គមកាន់តែច្រើនឡើងៗគួរកត់សម្គាល់។

## ២០-ការប្រយុទ្ធប្រឆាំងការរើសអើងជនជាតិដើមភាគតិច និងជនជាតិភាគតិច

(អនុសាសន៍លេខ ៤៨)

**៥៨**-ព្រះរាជាណាចក្រកម្ពុជា មានជនជាតិដើមភាគតិចចំនួន ២២អំបូរ និងជនជាតិភាគតិចជាង ៦០ជាតិសាសន៍។ គិតត្រឹមខែកញ្ញាឆ្នាំ២០២០ ជនជាតិដើមភាគតិចសរុបមានប្រមាណ ៤៥៥សហគមន៍ ដែលកំពុងរស់នៅក្នុង១៥រាជធានី-ខេត្ត ក្នុងនោះក្រសួងអភិវឌ្ឍន៍ជនបទ បានចេញលិខិតបញ្ជាក់ស្វ័យអត្តសញ្ញាណទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចចំនួន ១៧៧សហគមន៍ និងបានចូលរួមកិច្ចប្រជុំពេញអង្គរៀបចំបទបញ្ជាផ្ទៃក្នុងស្តីពីការប្រើប្រាស់ និងការគ្រប់គ្រងដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចបានចំនួន ៩៩សហគមន៍ នៅក្នុងខេត្តគោលដៅទាំង១៥ ដែលការរៀបចំបទបញ្ជាផ្ទៃក្នុងនេះ គឺជានីតិវិធីមួយដើម្បីទទួលបានបណ្ណកម្មសិទ្ធិដីសមូហភាព។ ជនជាតិដើមភាគតិចទាំងអស់ បានរក្សានូវឯកភាពជាតិពន្ធុសង្គម វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ជំនឿ ភាសា របៀបរបបរស់នៅផ្សេងៗគ្នានិងកំពុងរស់នៅយ៉ាងសុខដុមរមនាក្នុងសង្គម។

**៥៩**-ក្នុងការប្រយុទ្ធនឹងការរើសអើងប្រឆាំងនឹងជនជាតិដើមភាគតិច រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញគោលនយោបាយអភិវឌ្ឍន៍ជនជាតិដើមភាគតិច តាមរយៈការអនុវត្តកម្មវិធីនិងគម្រោងអភិវឌ្ឍន៍នានា ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ បានធ្វើឱ្យស្ថានភាពសេដ្ឋកិច្ច សង្គម

វប្បធម៌ ប្រពៃណី និងភាសាកំណើតរបស់ជនជាតិដើមភាគតិចនៅគ្រប់តំបន់មានការរីកចម្រើនជាបន្តបន្ទាប់ ជាអាទិ៍ ហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ សាលារៀន ទឹកស្អាត អគ្គិសនី មណ្ឌលសុខភាពនៅនឹងកន្លែង និងមណ្ឌលសុខភាពចល័ត ជាដើម។

**៦០**-ផ្អែកលើគោលនយោបាយខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានលើកកម្ពស់សិទ្ធិទទួលបានការអប់រំសម្រាប់កុមារជនជាតិដើមភាគតិច ដោយបានបង្កើតកម្មវិធីអប់រំពហុភាសា និងបានផ្តល់សេវាអប់រំពហុភាសាដល់កុមារជនជាតិដើមភាគតិចនៅកម្រិតមត្តេយ្យសិក្សា ១៤២កន្លែង និងបឋមសិក្សា ៩៦សាលា ព្រមទាំងបានបោះពុម្ពសៀវភៅសិក្សាអប់រំពហុភាសាថ្នាក់ទី១-៣ និងបានបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីបង្រៀនកុមារដែលជាជនជាតិដើមភាគតិចផងដែរ។ សិស្ស និស្សិតជនជាតិដើមភាគតិច ទទួលបានឱកាសសិក្សារហូតដល់កម្រិតឧត្តមសិក្សា តាមរយៈកម្មវិធីអាហារូបករណ៍ និងកម្មវិធីគាំទ្រផ្សេងៗទៀត។

## ២១-ការគ្រប់គ្រងគ្រោះមហន្តរាយ

(អនុសាសន៍លេខ ៦៨)

**៦១**-គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បាននិងកំពុងអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ដូចជា (១). បន្តពង្រឹង និងអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងសេចក្តីសម្រេចលេខ ០០១ ឆ្នាំ២០១៩, (២). បង្កើតក្រុមការងារយេនឌ័រ ដើម្បីពង្រឹងសមត្ថភាព និងការយកចិត្តទុកដាក់ដល់ស្ត្រី ក្នុងការចូលរួមធ្វើសកម្មភាពកាត់បន្ថយហានិភ័យគ្រប់គ្រងគ្រោះមហន្តរាយ និង (៣). បានដាក់បញ្ចូលការលើកកម្ពស់ និងការយកចិត្តទុកដាក់ចំពោះស្ត្រី កុមារ និងជនមានពិការភាព ក្នុងផែនការសកម្មភាពជាតិ ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឆ្នាំ២០១៩-២០២៣។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បាននិងកំពុងយកចិត្តទុកដាក់ក្នុងការអនុវត្តកិច្ចព្រមព្រៀងអាស៊ាន ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបគ្រោះអាសន្ន។

## ២២-កំណែទម្រង់ប្រព័ន្ធតុលាការ

(អនុសាសន៍លេខ ១២៤ និង ១២៧)

**៦២**-រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតច្បាប់ពាក់ព័ន្ធនឹងវិស័យតុលាការ ដោយគិតគូរអំពីគោលការណ៍គ្រឹះនៃយុត្តិធម៌ក្នុងការធានានូវឯករាជ្យភាពនៃអំណាចតុលាការ។ ក្រសួងយុត្តិធម៌ បានដាក់ឱ្យដំណើរការអង្គភាពរដ្ឋបាលតុលាការ ដែលទទួលបន្ទុកលើការងារបុគ្គលិក រដ្ឋបាលនិងហិរញ្ញវត្ថុរបស់អង្គការតុលាការ និងអង្គការអយ្យការគ្រប់ជាន់ថ្នាក់នៅតាមសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។ អង្គភាពរដ្ឋបាលតុលាការពុំមានអំណាចជ្រៀតជ្រែកកិច្ចការ និងជះឥទ្ធិពលលើសិទ្ធិជម្រះក្តីរបស់ចៅក្រមឡើយ។ ចៅក្រមធ្វើការជម្រះក្តីដោយឯករាជ្យតាមឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងក្របខណ្ឌច្បាប់។ រាជរដ្ឋាភិបាល បានដាក់ចេញនូវកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការឆ្លោះទៅសម្រេចចក្ខុវិស័យ ដើម្បីទទួលបានយុត្តិធម៌ទាំងអស់គ្នា តាមរយៈការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាយុត្តិធម៌ និងសិទ្ធិទទួលបានយុត្តិធម៌របស់ប្រជាពលរដ្ឋតាមរយៈ (១). ការពង្រឹងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ, (២). ការពង្រឹងភាពស្អាតស្អំនិងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់, (៣). ការពង្រឹងយន្តការវិន័យការងារ និងការធ្វើទំនើបកម្មរដ្ឋបាលយុត្តិធម៌, (៤). ការលើកកម្ពស់ការផ្តល់សេវាច្បាប់ និង (៥). ការពង្រឹងនិងកែលម្អយន្តការដោះស្រាយវិវាទ ដែលអាចឆ្លើយតបបានទៅនឹងស្ថានភាពជាក់ស្តែងរបស់សង្គមប្រកបដោយប្រសិទ្ធភាព។

**៦៣**-ក្រសួងយុត្តិធម៌ បានសហការជាមួយ OHCHR កំពុងដំណើរការពិនិត្យឡើងវិញ ដើម្បីកែលម្អច្បាប់មូលដ្ឋាន

ទាំង ៣ គឺច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម ដោយទទួលយកនូវអនុសាសន៍ផ្សេងៗពីដៃគូជាតិ និងអន្តរជាតិ។ ក្រសួង ក៏បានណែនាំឱ្យតុលាការប្រើប្រាស់គំរូ និងនីតិវិធីមួយចំនួននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) សម្រាប់លើកកម្ពស់ប្រសិទ្ធភាពការងារនៃតុលាការគ្រប់ជាន់ថ្នាក់ ដែលកន្លងមកបានដាក់ឱ្យប្រើប្រាស់រូបមន្តដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដោយយកលំនាំតាមដីកាសម្រេចរបស់ អ.វ.ត.ក.។

**២៣-ឯករាជ្យភាពតុលាការ**

(អនុសាសន៍លេខ ១១៨, ១២២, ១២៣ និង ១២៥)

**៦៤**-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បាននិងកំពុងអនុវត្តគោលការណ៍ផ្លាស់ប្តូរទីកន្លែងធ្វើការរបស់ចៅក្រម ៤ឆ្នាំម្តង ដាក់ពិន័យដល់ចៅក្រម ឬព្រះរាជអាជ្ញា ដែលមិនគោរពវិជ្ជាជីវៈនិងក្រមសីលធម៌ ពង្រឹងការអនុវត្តវិន័យចៅក្រមនិងព្រះរាជអាជ្ញា ចុះអធិការកិច្ចតាមសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងពិនិត្យឡើងវិញក្រមសីលធម៌ចៅក្រមនិងព្រះរាជអាជ្ញា ដើម្បីឱ្យចៅក្រមប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនត្រឹមត្រូវតាមច្បាប់ ក្នុងការសម្រេចសេចក្តីដោយឯករាជ្យនិងយុត្តិធម៌។

**២៤-ការបង្កើតសាលាឧទ្ធរណ៍តំបន់**

(អនុសាសន៍លេខ ១២០)

**៦៥**-បន្ថែមលើសាលាឧទ្ធរណ៍ភ្នំពេញ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានចេញព្រះរាជក្រឹត្យប្រកាសដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ចំនួន ៣ គឺសាលាឧទ្ធរណ៍បាត់ដំបង សាលាឧទ្ធរណ៍ត្បូងឃ្មុំ និងសាលាឧទ្ធរណ៍ព្រះសីហនុ ដោយបានចាប់ផ្តើមប្រតិបត្តិការចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២០។ ក្រសួងយុត្តិធម៌ ក៏បាននិងកំពុងពិចារណាបង្កើតសាលាឧទ្ធរណ៍តំបន់បន្ថែមទៀតតាមតម្រូវការចាំបាច់។

**២៥-ការពន្លឿននីតិវិធីជំនុំជម្រះដើម្បីកាត់បន្ថយពេលវេលាឃុំខ្លួនបណ្តោះអាសន្ន**

(អនុសាសន៍លេខ ១២៦)

**៦៦**-ក្រសួងយុត្តិធម៌ បានដាក់ចេញយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី-ខេត្ត ដោយដាក់ចេញនូវវិធានការណែនាំឱ្យអនុវត្តនៅក្នុងដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ដើម្បីធានាប្រសិទ្ធភាពនៃយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនេះ។

**៦៧**-ចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ សាលាដំបូងរាជធានី-ខេត្តទូទាំងប្រទេស បានដោះស្រាយសំណុំរឿងព្រហ្មទណ្ឌ ដែលកកស្ទះទាំងក្នុងដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ បានចំនួន ៣៧ ៩០០រឿង ស្មើនឹង ៩៦% នៃសំណុំរឿងជាង ៣៩ ៥០០ ក្នុងនោះ សំណុំរឿងដែលបានជំនុំជម្រះរួចមានចំនួនជាង ១២ ៦០០រឿង ស្មើនឹង ៩៧% នៃចំនួនសំណុំរឿងជាង ១៣ ០០០រឿង និងដោះស្រាយសំណុំរឿងព្រហ្មទណ្ឌចូលថ្មីបានចំនួនជាង ៦២ ៨០០ រឿង ស្មើនឹងជាង ៧៨% នៃសំណុំរឿងសរុបជាង ៨០ ៤០០រឿង។

**២៦-អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

(អនុសាសន៍លេខ ១៣៤)

**៦៨**-នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ជនរងគ្រោះមានសិទ្ធិស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងអាចទាមទារសំណងដែលមានលក្ខណៈ «សមូហភាព និងផ្លូវចិត្ត» ក្នុងគោលបំណង

ស្តារកិត្តិយសរបស់ជនរងគ្រោះឡើងវិញ ដោយការបង្កើតការចងចាំជាសមូហភាព និងការផ្តល់ការទទួលស្គាល់ជាផ្លូវការជូនជនរងគ្រោះ។ គម្រោងចំនួន ២២ ក្នុងសំណុំរឿង០០២/០២ ត្រូវបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង (អ.ជ.ស.ដ.) ប៉ុន្តែ មានតែគម្រោងចំនួន ១៣ប៉ុណ្ណោះ ដែល អ.ជ.ស.ដ. សម្រេចផ្តល់ជាសំណង។ គម្រោងសំណងទាំងនោះត្រូវបានកំណត់ទៅជា៣ផ្នែកចម្បងៗ ដូចជា ការអប់រំ ការចងចាំ និងការស្តារនីតិសម្បទា។

**៦៩**-ក្នុងចំណោមគម្រោងទាំង ១៣ ដែលត្រូវបានអនុវត្តសម្រាប់ផលប្រយោជន៍រួម មានគម្រោងចំនួន ៣ ត្រូវបានរៀបចំឡើង ដើម្បីអនុវត្តឱ្យបានជាក់លាក់សម្រាប់ផលប្រយោជន៍របស់ជនរងគ្រោះដោយសារអំពើប្រល័យពូជសាសន៍ រួមមាន គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍ (ជនជាតិចាម និងអតីតខ្មែរក្រហម), គម្រោងសំឡេងពីជនជាតិភាគតិច និងគម្រោងការអប់រំផ្នែកច្បាប់និងសិទ្ធិពលរដ្ឋដល់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិច។ បច្ចុប្បន្ន អ.វ.ត.ក. បាននិងកំពុងតែអនុវត្តមុខងារនៅសេសសល់របស់ខ្លួន ជាពិសេសពាក់ព័ន្ធទៅនឹងកិច្ចការពារដល់ជនរងគ្រោះនិងសាក្សី, ការពិនិត្យមើលការអនុវត្តការងារសំណង ដែលបានផ្តល់ជូនដល់ដើមបណ្តឹងរដ្ឋប្បវេណី, ការផ្សព្វផ្សាយអំពីសមិទ្ធផលការងារសម្រេចបានរបស់ អ.វ.ត.ក. ដល់សាធារណជនឱ្យទូលំទូលាយ និងការរក្សាទុកនិងគ្រប់គ្រងបណ្ណសារ។

## ២៧-ការប្រយុទ្ធប្រឆាំងអំពើពុករលួយ

(អនុសាសន៍លេខ ១២៩)

**៧០**-តាមរយៈផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយដំណាក់កាលទី៣ ឆ្នាំ២០២០-២០២៥ អង្គភាពប្រឆាំងអំពើពុករលួយ បាននិងកំពុងអនុវត្តការងារអាទិភាពចំនួន ៣ គឺ អប់រំ បង្ការទប់ស្កាត់ និងអនុវត្តច្បាប់បង្ក្រាប។ ការងារទាំងនេះ នឹងត្រូវបំពេញបន្ថែមដោយការងារអាទិភាពមួយចំនួនទៀត ជាអាទិ៍ ប្រសិទ្ធភាពការអនុវត្តច្បាប់, លើកស្ទួយភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈនិងវិស័យឯកជន, ចូលរួមពីសំណាក់ភាគីពាក់ព័ន្ធ និងសហគមន៍អន្តរជាតិលើការងារប្រយុទ្ធប្រឆាំងអំពើពុករលួយនិងប្រឆាំងការសម្អាតប្រាក់, អភិបាលកិច្ចនិងការត្រួតពិនិត្យផ្ទៃក្នុងឱ្យកាន់តែមានប្រសិទ្ធភាព។ សកម្មភាពជាអាទិភាពដែលកំពុងអនុវត្ត មាន៖ (១). ការធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់ ដើម្បីធានាប្រសិទ្ធភាពនៃការប្រឆាំងអំពើពុករលួយ, (២). ពង្រឹងអភិបាលកិច្ច និងប្រសិទ្ធភាពលទ្ធកម្មសាធារណៈ, (៣). ផ្តល់សេវាល្អក្នុងក្របខណ្ឌសាធារណៈ និងធុរកិច្ចស្អាតស្អំក្នុងវិស័យឯកជន, (៤). ជំរុញកិច្ចសហការជាតិ និងអន្តរជាតិលើការប្រឆាំងអំពើពុករលួយ ការសម្អាតប្រាក់ និងការរឹបអូសផលនៃបទល្មើស និង (៥). ជំរុញសុចរិតភាពស្ថាប័នសាធារណៈ ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយដំណាក់កាលទី៣។

## ២៨-ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

(អនុសាសន៍លេខ ៦៩-៧៧, ១៧១ និង ១៩១)

**៧១**-ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជរដ្ឋាភិបាល បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០១៩-២០២៣)។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ ដោយបានចុះអនុស្សរណៈយោគយល់គ្នា និងកិច្ចព្រមព្រៀងជាមួយដៃគូនានា ឆ្នាំ២០១៩-២០២៣ មានប្រមាណចំនួន១៨។

**៧២**-គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានធ្វើការផ្សព្វផ្សាយតាមសណ្ឋាគារ ផ្ទះសំណាក់

កន្លែងផ្តល់សេវាកម្សាន្ត និងបង្កើតប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ និងហ្វេសប៊ុកផេក សម្រាប់ទទួលព័ត៌មានបណ្តឹង និងអន្តរាគមន៍ជួយជនរងគ្រោះ ព្រមទាំងសហការជាមួយអង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ដើម្បីបង្ការនិងទប់ស្កាត់បទល្មើសផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ។ គិតពីឆ្នាំ២០១៩ ដល់ឆមាសទី១ ឆ្នាំ២០២៣ ការផ្សព្វផ្សាយស្តីពីការបង្ការទប់ស្កាត់បានចំនួន ៥៥០ ០៤៧លើក និងសរុបអ្នកចូលរួមប្រមាណ ៣០ ៤៣៨ ៥១៨នាក់។ ស្នងការដ្ឋាននគបាលរាជធានី-ខេត្ត បានធ្វើការល្បាតឃ្លាំមើលគោលដៅដែលមានការសង្ស័យបានចំនួន ១ ៧៩១លើក ព្រមទាំងបានពង្រឹងការងារចុះធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសនៅតាមសណ្ឋាគារ ផ្ទះសំណាក់ ហាងខារ៉ាអូខេ និងម៉ាស្សាបានចំនួន ១២ ៣៤៣គោលដៅដែលមានអ្នកពាក់ព័ន្ធចំនួន ៩៨ ៥១១នាក់។

**៧៣**-តាមរយៈការពង្រឹងការអនុវត្តច្បាប់ពីឆ្នាំ២០១៩ ដល់ឆមាសទី១ ឆ្នាំ២០២៣ អាជ្ញាធរមានសមត្ថកិច្ចបង្ក្រាបអំពើពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន ៩៣៦ករណី ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅតុលាការបានចំនួន ១ ២៥៨ នាក់ និងសង្គ្រោះជនរងគ្រោះបានចំនួន ៣ ១៣៩នាក់។ ក្នុងរយៈពេលនេះដែរ តុលាការមានសំណុំរឿងពាក់ព័ន្ធចំនួន ១ ៦១៦ករណី ដែលមានជនរងគ្រោះចំនួន ១ ៧៩៣នាក់ និងជនជាប់ចោទសរុបចំនួន ២ ៤៥៣នាក់ ហើយចាត់ការរួចបាន ៨៤៧សំណុំរឿង ដោយបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារជនល្មើសចំនួន ៧៩១នាក់ និងកំពុងបន្តចាត់ការ ៧៦៩សំណុំរឿង។ ក្នុងរយៈពេលដដែលនេះ មានជនរងគ្រោះនិងជនងាយរងគ្រោះ ដោយអំពើជួញដូរមនុស្សគ្រប់ទម្រង់ចំនួន ៥ ៥៧៩នាក់ បាននិងកំពុងធ្វើការស្តារនីតិសម្បទានៅមណ្ឌលរបស់អង្គការដៃគូ និង ១ ០៦៣នាក់ទៀតត្រូវបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ។

**៧៤**-តាមរយៈគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់រាជរដ្ឋាភិបាល ដែលជាយន្តការជាតិតែមួយគត់មាន ២២ក្រសួង និង៥អង្គភាពជំនាញជាសមាជិក មានតួនាទីចម្បងក្នុងការដាក់ចេញនូវគោលនយោបាយ ផែនការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងវិធានការនានាដើម្បីឱ្យស្ថាប័នជំនាញពាក់ព័ន្ធរួមគ្នាអនុវត្ត ហើយធ្វើការពិនិត្យតាមដាននិងវាយតម្លៃប្រសិទ្ធភាព ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយប្រទេសពាក់ព័ន្ធនានាក្នុងអនុតំបន់ តំបន់ និងក្នុងពិភពលោក ក៏ដូចជាអង្គការសង្គមស៊ីវិល និងដៃគូជាតិ និងអន្តរជាតិ អង្គការសហប្រជាជាតិប្រឆាំងការជួញដូរមនុស្ស ដើម្បីរួមគ្នាអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង (UNTOC), អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស (ACTIP), ផែនការកម្មវិធីអាស៊ាន, កតិកាសញ្ញាពិភពលោកស្តីពីទេសន្តប្រវេសន៍ប្រកបដោយសុវត្ថិភាព របៀបរៀប និងស្របច្បាប់(GCM) តាមរយៈក្រុមការងារអាស៊ានប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន រួមទាំងអំពើជួញដូរមនុស្ស (SOMTC), គណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិស្ត្រីនិងកុមារ (ACWC), ក្រុមការងារចំពោះកិច្ចសម្រាប់កិច្ចសហការប្រឆាំងការជួញដូរមនុស្សក្នុងអនុតំបន់មេគង្គ (COMMIT)។ កម្ពុជាក៏ជាប្រទេសសមាជិកនៃបណ្តាញទេសន្តប្រវេសន៍ថ្នាក់តំបន់ និងអន្តរជាតិ (UN and Regional Migration Network) និងជាប្រទេសឈានមុខក្នុងការអនុវត្ត GCM (Champion Country) ផងដែរ។

**៧៥**-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងរៀបចំគោលការណ៍ណែនាំស្តីពីយន្តការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សដល់ក្រសួង/ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនដែលពាក់ព័ន្ធ សម្រាប់អនុវត្តឱ្យស្របតាមគោលនយោបាយជាតិ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សឆ្នាំ២០០៩។

**៧៦**-ក្នុងឆ្នាំ២០២២ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាន៖ (ក). ទទួលនិងបញ្ជូនជនរងគ្រោះនិងងាយរងគ្រោះប្រមាណ ២ ២១៨នាក់ (ប្រុស ៣៦នាក់ ស្រី ៦៧៤នាក់ កុមារា ៥៩៨នាក់ កុមារី ៩០៧នាក់) ទៅស្តារនីតិសម្បទានៅមណ្ឌលរបស់អង្គការដៃគូ។ (ខ). ទទួលជនរងគ្រោះនិងងាយរងគ្រោះ ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាតាមផ្លូវអាកាសសរុប ២៨៨នាក់ (ប្រុស ៦១នាក់ ស្រី ២០៣នាក់ កុមារា ០៣នាក់ កុមារី ២១នាក់) និង (គ). ទទួលជនរងគ្រោះ និងងាយរងគ្រោះជាជនជាតិបរទេសនៅក្នុងស្រុក ចំនួន ១០នាក់ (ប្រុស ៩នាក់ ស្រី ១នាក់)។

## ២៩-ការត្រួតពិនិត្យថ្នាក់ជាតិ

(អនុសាសន៍លេខ ៣៣)

**៧៧**-រាជរដ្ឋាភិបាលកម្ពុជា បានចេញសេចក្តីសម្រេចលេខ ៩២ ឆ្នាំ២០១៩ ដោយបង្កើនសមាសភាពគណៈកម្មាធិការជាតិត្រួតពិនិត្យរហូតដល់ចំនួន ២៣រូប។ គណៈកម្មាធិការជាតិមានតួនាទីនិងភារកិច្ច ដូចជា ពិនិត្យ និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលទាក់ទងនឹងការផ្តល់សច្ចាប័ន ឬការដកខ្លួនចេញ, តាមដាន និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលក្នុងការធ្វើរបាយការណ៍ជូនស្ថាប័នអន្តរជាតិ, រៀបចំរបាយការណ៍បំភ្លឺករណីបណ្តឹងនានា, ពិនិត្យ និងចាត់ចែងការចុះស្រាវជ្រាវលើអង្គហេតុ និងអង្គច្បាប់ ប្រមូលព័ត៌មាន និងភស្តុតាងនៃករណីបណ្តឹងនានា, ព្រមទាំងសម្របសម្រួល និងចាត់ចែងឱ្យមានការដោះស្រាយបញ្ហានានា, ពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារ និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ។

## ៣០-ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

(អនុសាសន៍លេខ ១២, ២៤-២៩ និង១០៩)

**៧៨**-កាលពីអំឡុងចុងខែតុលាឆ្នាំ២០២២ ក្រុមការងាររបស់រាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល បានបន្តជួបពិភាក្សាពិគ្រោះយោបល់ដំណាក់កាលទី២ ជាមួយតំណាងអង្គការសង្គមស៊ីវិល ដោយមានការអញ្ជើញចូលរួមពីតំណាងស្ថានទូត និងដៃគូអភិវឌ្ឍន៍ផងដែរ ដើម្បីបន្តធ្វើការពិនិត្យពិភាក្សាលើសេចក្តីព្រាងខ្លឹមសារវិសោធនកម្មចំនួន១៦មាត្រា នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល រួមមាន៖ មាត្រា១, ៧-១១, ២០, ២១, ២៤-២៦, ៣០-៣២, ៣៥ និង ៣៦។ ជាលទ្ធផលបានកែសម្រួលរួចហើយលើមាត្រាចំនួន ៩ និងមាត្រាចំនួន ៧ទៀត ដូចជា មាត្រា៩-១១, ២០, ២១, ២៤ និង៣៦ ត្រូវបានតំណាងអង្គការសង្គមស៊ីវិលស្នើសុំធ្វើការពិនិត្យពិភាក្សាផ្ទៃក្នុងឡើងវិញ។ ជាមួយគ្នានេះ ភ្នាក់ងារកុងស៊ុលនិងការិយាល័យសហប្រតិបត្តិការស្វីសប្រចាំនៅកម្ពុជា បានផ្តល់អ្នកជំនាញអន្តរជាតិដើម្បីធ្វើការវិភាគផ្នែកច្បាប់នៅក្នុងក្របខណ្ឌនៃដំណើរការធ្វើវិសោធនកម្មច្បាប់នេះផងដែរ។

## ៣១-ច្បាប់ស្តីពីសហជីព

(អនុសាសន៍លេខ ២៦, ២៧, ២៩, ១០៩ និង ១៥១-១៥៣)

**៧៩**-ដើម្បីធ្វើឱ្យនីតិវិធីនៃការចុះបញ្ជីសហជីពមានភាពសាមញ្ញ និងឆាប់រហ័សជាងមុន ច្បាប់ស្តីពីសហជីពត្រូវបានធ្វើវិសោធនកម្មចំនួន ១០មាត្រា នៅឆ្នាំ២០២០។ ការធ្វើវិសោធនកម្មច្បាប់នេះ គឺជាការសំយោគធាតុចូលដែលផ្តល់ដោយភាគីពាក់ព័ន្ធ រួមមាន សហជីព និយោជក និងអង្គការអន្តរជាតិខាងការងារ។ សិទ្ធិនិងភារកិច្ចរបស់សហជីពភាគតិច ក្នុងការតំណាងសមាជិករបស់ខ្លួននៅក្នុងការដោះស្រាយវិវាទការងាររួម ដែលមិនកើតចេញពីការអនុវត្តអនុសញ្ញារួមក៏ត្រូវបានបញ្ជាក់ឱ្យកាន់តែច្បាស់ផងដែរ។

**៨០**-ត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣ ការចុះបញ្ជីអង្គការវិជ្ជាជីវៈនៅតែបន្តកើនឡើង ដោយមានអង្គការវិជ្ជាជីវៈចុះបញ្ជី

ចំនួន ៦ ២៥៣ ក្នុងនោះរួមមាន សហជីពមូលដ្ឋានមានចំនួន ៥ ៩២១, សហព័ន្ធសហជីពមានចំនួន ២៧៨, សហភាពសហជីពមានចំនួន ៤២, និងសមាគមនិយោជកមានចំនួន ១២។ មុនពេលមានច្បាប់ស្ដីពីសហជីព ឆ្នាំ២០១៦ អង្គការវិជ្ជាជីវៈដែលបានចុះបញ្ជិការមានចំនួនតែ ៣ ៦២៤, នៅឆ្នាំ២០១៧ អង្គការវិជ្ជាជីវៈបាន កើនដល់ ៤ ៣០៧ (កើន ១៨,៧៨%) និងក្រោយធ្វើវិសោធនកម្មច្បាប់ស្ដីពីសហជីពឆ្នាំ២០២០ អង្គការវិជ្ជាជីវៈ បានកើនដល់ ៥ ៤៨៤ (កើន ២៧,៣៣%)។ បើប្រៀបធៀបមុនពេលមានច្បាប់ស្ដីពីសហជីពក្នុងឆ្នាំ២០១៦ និងក្រោយពេលមានច្បាប់នេះគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣ ចំនួនអង្គការវិជ្ជាជីវៈមានកំណើន ៧២,៤០%។

**៣២-ច្បាប់ស្ដីពីទូរគមនាគមន៍**

(អនុសាសន៍លេខ ២៦, ២៩ និង៩៦)

**៨១**-ច្បាប់ស្ដីពីទូរគមនាគមន៍ឆ្នាំ២០១៥ បានរៀបចំឡើងដោយមានការចូលរួមពិគ្រោះយោបល់ជាច្រើនលើក ច្រើនសាជាមួយអង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា ព្រមទាំងទទួលបាននូវធាតុចូលនានាពីអ្នកជំនាញ ផ្ទៃក្នុងក្រសួង អន្តរក្រសួង វិស័យឯកជន តំណាងស្ថានទូតជប៉ុននៅកម្ពុជា អង្គការ JICA សហភាព ទូរគមនាគមន៍អន្តរជាតិ ព្រមទាំងបានធ្វើការប្រៀបធៀប និងដកស្រង់ខ្លឹមសារនៃច្បាប់ស្ដីពីទូរគមនាគមន៍ពី បណ្ដាប្រទេសជាច្រើននៅក្នុងតំបន់អាស៊ាន ជប៉ុន និងកូរ៉េខាងត្បូង ដែលធ្វើឱ្យច្បាប់នេះស្របទៅនឹងកាតព្វកិច្ច អន្តរជាតិរបស់កម្ពុជា។

**៣៣-ច្បាប់ស្ដីពីសិទ្ធិទទួលព័ត៌មាន**

(អនុសាសន៍លេខ ៩៦)

**៨២**-បន្ទាប់ពីបានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយអង្គការសង្គមស៊ីវិល និងក្រសួង/ស្ថាប័នពាក់ព័ន្ធ ដូចជា ក្រុម ប្រឹក្សាអ្នកច្បាប់នៃទីស្ដីការគណៈរដ្ឋមន្ត្រី និងក្រសួងយុត្តិធម៌ ក្រសួងព័ត៌មានបានកែសម្រួលសេចក្ដីព្រាងច្បាប់ នេះចប់សព្វគ្រប់ ដោយមាន ១០ជំពូក និង ៤២មាត្រា ហើយក្រសួងកំពុងជំរុញក្នុងការពន្លឿននីតិវិធីផ្សេងៗ ទៀត ដើម្បីឱ្យសេចក្ដីព្រាងច្បាប់នេះចេញនាពេលខាងមុខ។

**៣៤-ច្បាប់ស្ដីពីគណបក្សនយោបាយ**

(អនុសាសន៍លេខ ២៥-២៧ និង ១០៩)

**៨៣**-ច្បាប់ស្ដីពីគណបក្សនយោបាយ ត្រូវបានធ្វើវិសោធនកម្មចំនួន ៣លើក។ វិសោធនកម្មលើកទី១ នៅខែ មីនា ឆ្នាំ២០១៧ និងលើកទី២ នៅខែកក្កដា ឆ្នាំ២០១៧។ វិសោធនកម្មទាំងពីរលើកនេះ បានផ្ដល់អំណាច ដល់តុលាការកំពូល ក្នុងការផ្អាកសកម្មភាពគណបក្សនយោបាយ ឬរំលាយគណបក្សនយោបាយ តាមបណ្ដឹង របស់ក្រសួងមហាផ្ទៃ ក្នុងករណីដែលគណបក្សនយោបាយនោះ ប្រព្រឹត្តល្មើសនឹងមាត្រា៦ថ្មី(ពីរ) មាត្រា៧ មាត្រា២៩ថ្មី និងមាត្រា៣៨ថ្មី។ ចំណែកឯវិសោធនកម្មលើកទី៣ ធ្វើឡើងនៅខែមករា ឆ្នាំ២០១៩ ក្នុងគោល បំណងផ្ដល់សិទ្ធិឱ្យបុគ្គល ដែលត្រូវបានតុលាការសម្រេចហាមឃាត់ការធ្វើសកម្មភាពនយោបាយ ឱ្យទទួល បាននូវសិទ្ធិនយោបាយពេញលេញឡើងវិញ បន្ទាប់ពីផុតរយៈពេលនៃការហាមឃាត់ដោយតុលាការកំពូល និង ក្នុងករណីដែលបុគ្គលនោះ ត្រូវបានផ្ដល់នីតិសម្បទាធ្វើសកម្មភាពនយោបាយឡើងវិញដោយព្រះមហាក្សត្រ តាមសំណើរបស់នាយករដ្ឋមន្ត្រី។

**៣៥-សេរីភាពនៃការបញ្ចេញមតិ**

(អនុសាសន៍លេខ ៨១, ៨៣, ៨៦, ៨៧, ៩៣-៩៥, ៩៨, ៩៩, ១០១, ១០៥-១០៧ និង ១១០)

**៨៤**-ប្រកាសអន្តរក្រសួងលេខ១៧០ ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងការផ្សាយតាមគេហទំព័រ និងបណ្ដាញ

ទំនាក់ទំនងសង្គមតាមប្រព័ន្ធអ៊ីនធឺណិតនៅព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីវិធានការគ្រប់គ្រងដើម្បីប្រឆាំងទប់ស្កាត់រាល់ការផ្សព្វផ្សាយ ឬចែកចាយខ្លឹមសារព័ត៌មាន ឬសារជាអក្សរ សំឡេង រូបភាព វីដេអូ និង/ឬទម្រង់ផ្សេងៗតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលមានចេតនាបង្កជាចលាចលក្នុងសង្គម បណ្តាលឱ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សេដ្ឋកិច្ចជាតិ សណ្តាប់ធ្នាប់សាធារណៈ ការរើសអើង ប៉ះពាល់ដល់វប្បធម៌ និងប្រពៃណីជាតិ។ នេះមិនមែនជាការព្យាយាមរារាំងចំពោះសិទ្ធិទទួលព័ត៌មាន និងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិតាមរយៈបណ្តាញសារព័ត៌មាន និងអ៊ីនធឺណិតនោះទេ។ ក្នុងក្របខណ្ឌច្បាប់ សេរីភាពនៃការបញ្ចេញមតិនៅកម្ពុជាត្រូវបានការពារ និងលើកកម្ពស់ដោយច្បាប់។ យោងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានធានាការពារសិទ្ធិសេរីភាពបញ្ចេញមតិចំពោះប្រជាពលរដ្ឋគ្រប់រូប ។ ច្បាប់ស្តីពីរបបសារព័ត៌មាន ក៏បានកំណត់នូវសេរីភាពខាងការសរសេរ និងការបោះពុម្ពផ្សាយ មិនត្រូវឱ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់អ្នកដទៃផងដែរ។

៨៥-ដើម្បីធ្វើឱ្យប្រសើរឡើងនូវការធ្វើសកម្មភាពរបស់អង្គការសង្គមស៊ីវិល រាជរដ្ឋាភិបាលបានសម្រេចរៀបចំវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ព្រមទាំងបានបង្កើតក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បីសម្របសម្រួលដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល ក្នុងគោលបំណងបង្ហាញពីភាពជាដៃគូមានលក្ខណៈស្មោះត្រង់និងពិតប្រាកដ។

៨៦-ជាមួយគ្នានេះ ក្រសួងមហាផ្ទៃបានណែនាំដល់រដ្ឋបាលរាជធានី-ខេត្ត ឱ្យគាំទ្រដល់ការអនុវត្តសកម្មភាពរបស់អង្គការសង្គមស៊ីវិល ដោយបានដាក់ចេញនូវសេចក្តីណែនាំលេខ ០៤០ និងលិខិតលេខ ២០០៦ ក្នុងឆ្នាំ២០១៨ ដើម្បីធានាឱ្យសមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នានានៅមូលដ្ឋាន មានសិទ្ធិសេរីភាពពេញលេញ ក្នុងការធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ព្រមទាំងលក្ខន្តិកៈរបស់ខ្លួនដែលបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយពុំចាំបាច់ជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាននោះឡើយ។ ក្រសួងក៏បានកំណត់ឱ្យរដ្ឋបាលរាជធានី-ខេត្ត ត្រូវរៀបចំវេទិកាពិគ្រោះយោបល់ជាមួយនឹងអង្គការសង្គមស៊ីវិល ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យបានទៀងទាត់រៀងរាល់ឆមាស ឬតាមការចាំបាច់។

៨៧-រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងមហាផ្ទៃ នៅតែប្តេជ្ញាចិត្តបន្តរៀបចំវេទិកាភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលឱ្យបានចំនួន ២លើកក្នុងមួយឆ្នាំ ដើម្បីរួមគ្នាពង្រឹងនូវដំណើរការលទ្ធិប្រជាធិបតេយ្យ ការលើកកម្ពស់នូវសិទ្ធិមនុស្ស និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព ដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ ជាក់ស្តែង បន្ទាប់ពីស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩ មានភាពធូរស្រាលនិងស្ថិតក្នុងការគ្រប់គ្រងបាន ក្រសួងមហាផ្ទៃបានសម្រេចបន្តរៀបចំវេទិកាស្តីពីភាពជាដៃគូនេះឡើងវិញ កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ ។ ទន្ទឹមនេះ រដ្ឋបាលរាជធានី-ខេត្តក៏បានចាប់ផ្តើមរៀបចំវេទិកាពិគ្រោះយោបល់ជាមួយសមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន ដែលធ្វើសកម្មភាពក្នុងមូលដ្ឋានឡើងវិញជាបន្តបន្ទាប់ផងដែរ។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមានចំនួនសរុប ៦ ២៧៩ (សមាគម ២ ៧៤៧ និងអង្គការមិនមែនរដ្ឋាភិបាល ៣ ៥៣២)។

៨៨-ក្រសួងមហាផ្ទៃ បានបន្តទទួលយកនូវរាល់កង្វល់ សំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល ដើម្បីធ្វើការពិភាក្សាសម្របសម្រួលស្វែងរកដំណោះស្រាយ និងបានសហការជាមួយអង្គការ UNDP ក្នុងការអនុវត្តគម្រោងមានឈ្មោះថា «ការកសាងសមត្ថភាពសម្រាប់បង្កលក្ខណៈឱ្យមានការចូលរួមពីប្រជាពលរដ្ឋ ការកសាង

សន្តិភាព និងកិច្ចសន្ទនាប្រកបដោយបរិយាប័ន្នៈ ឆ្ពោះទៅរកអភិបាលកិច្ចប្រកបដោយបរិយាប័ន្ន និងប្រកបដោយការចូលរួម» សម្រាប់រយៈពេល៣ឆ្នាំ (២០២០-២០២៣)។ គម្រោងនេះ នឹងជួយអភិវឌ្ឍសមត្ថភាពបន្ថែមសម្រាប់មន្ត្រីរាជការសាធារណៈនៅរដ្ឋបាលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល ដើម្បីលើកកម្ពស់ភាពជាដៃគូរវាងមន្ត្រីរាជការ និងអង្គការសង្គមស៊ីវិល។

**៣៦-សកម្មជនសង្គមស៊ីវិល និងសមាជិកគណបក្សប្រឆាំង**

(អនុសាសន៍លេខ ៨៥, ១១២-១១៦ និង ១៣៣)

**៨៩**-អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស សកម្មជនដីធ្លី សកម្មជនបរិស្ថាន សកម្មជនសហជីព និងសមាជិកបក្សប្រឆាំង ក៏ដូចប្រជាពលរដ្ឋទូទៅ មានសិទ្ធិសេរីភាពនិងការទទួលខុសត្រូវ ជាពិសេស ការអនុវត្តតួនាទីភារកិច្ចនិងកាតព្វកិច្ចរបស់ខ្លួន ត្រូវស្របតាមការកំណត់របស់ច្បាប់។ រាល់សកម្មភាពដែលជ្រកក្រោមស្លាកសិទ្ធិមនុស្ស ហើយប្រព្រឹត្តអំពើល្មើស រំលោភបំពានរដ្ឋធម្មនុញ្ញ ច្បាប់ព្រហ្មទណ្ឌនិងច្បាប់នានា ប៉ះពាល់ដល់សន្តិសុខជាតិ សណ្តាប់ធ្នាប់សង្គម និងផលប្រយោជន៍សាធារណៈ ជនល្មើសត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។ ការអនុវត្តច្បាប់ប្រឆាំងជនល្មើស គឺជាការពង្រឹងនីតិរដ្ឋក្នុងសង្គមប្រជាធិបតេយ្យសេរី ធានានូវសមភាពចំពោះមុខច្បាប់ យុត្តិធម៌សង្គម គ្មាននិទណ្ឌភាព និងការគោរពតាមគោលការណ៍សិទ្ធិមនុស្ស។

**៩០**-កាលពីខែតុលា ឆ្នាំ២០២១ អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស សកម្មជនដីធ្លី សកម្មជនបរិស្ថានសកម្មជនសហជីព និងសមាជិកបក្សប្រឆាំងមួយចំនួនដែលបានប្រព្រឹត្តល្មើសច្បាប់ ត្រូវបានតុលាការចេញសេចក្តីសម្រេចដោះលែងឱ្យនៅក្រៅឃុំ ដោយដាក់ឱ្យឋិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយសកម្មជនមួយចំនួនទៀត ត្រូវបានដោះលែងបន្ទាប់ពីអនុវត្តទោសរបស់ខ្លួនបានចប់រួចរាល់។ អាជ្ញាធរមានសមត្ថកិច្ច បាន និងកំពុងប្រឹងប្រែងចាត់វិធានការតាមផ្លូវច្បាប់ទៅលើជនល្មើស ដែលប្រព្រឹត្តការរំលោភបំពានសិទ្ធិមនុស្សគ្រប់រូបភាព។

**៣៧-លំហរនយោបាយ និងប្រជាធិបតេយ្យ**

(អនុសាសន៍លេខ ៨០, ៨៨, ៩០, ៩១, ១០២ និង ១០៣)

**៩១**-ក្រសួងមហាផ្ទៃបានចេញលិខិតលេខ ៣១៦ ក្នុងឆ្នាំ២០២២ ណែនាំឱ្យអាជ្ញាធរមានសមត្ថកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង្កលក្ខណៈងាយស្រួលដល់គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីរួចហើយ ធ្វើសកម្មភាពស្របតាមច្បាប់ ដើម្បីចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

**៩២**-គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៣ គណបក្សនយោបាយចុះឈ្មោះក្នុងបញ្ជីនៅក្រសួងមហាផ្ទៃ មានចំនួន ៤៧គណបក្ស ដែលបានធ្វើសកម្មភាពដោយសេរី និងគ្មានការគំរាមកំហែងស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្នុងការចូលរួមប្រកួតប្រជែងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ កាលពីឆ្នាំ២០២២ ដែលមានគណបក្សនយោបាយចំនួន ១៧ បានចូលរួម និងមានបេក្ខជនសរុប ៨៦ ០៩២នាក់។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតចំនួន ៧ ៣៩៤ ៤២៧នាក់ ស្មើនឹង ៨០,៣២% នៃអ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ហើយជាលទ្ធផលមានគណបក្សនយោបាយចំនួន ៩ ទទួលបានអាសនៈសរុបចំនួន ១១ ៦២២ ជាក្រុមប្រឹក្សានៃឃុំ-សង្កាត់ ទាំង ១ ៦៥២។ ទន្ទឹមនេះ មានគណបក្សនយោយបាយចំនួន ១៨ បានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣។

៩៣-ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ដែលបានបង្កើតឡើងកាលពីឆ្នាំ២០១៨ បានចូលរួមចំណែកយ៉ាងសំខាន់ជាមួយរាជរដ្ឋាភិបាល។ ហេតុនេះក្នុងឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានសម្រេចបង្កើតក្រុមប្រឹក្សានេះជាថ្មី ដោយអនុញ្ញាតឱ្យមានសមាសភាពពីគណបក្សនយោបាយចូលរួមការបោះឆ្នោតឆ្នាំ២០២៣ និងគណបក្សផ្សេងទៀតដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ជាធរមាន។ យន្តការនេះ បង្កើតឡើងក្នុងគោលបំណងលើកស្ទួយរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ដើម្បីប្រមូលផ្តុំចូលនៃទស្សនៈពហុគំនិតជាប្រយោជន៍ដល់ការស្ថាបនាជាតិ។

**៣៨- កំណែទម្រង់ការបោះឆ្នោត**

(អនុសាសន៍លេខ ១២៣,១៣៨ និង ១៣៩)

៩៤-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដែលជាស្ថាប័នឯករាជ្យ ដូចមានចែងក្នុងមាត្រា ១៥០ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ បានអនុវត្តភារកិច្ចរបស់ខ្លួនដោយឯករាជ្យនិងអព្យាក្រឹត ក្នុងការធានារាល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតផ្សេងៗទៀតតាម ការកំណត់នៃច្បាប់។ គ.ជ.ប បានធ្វើទំនើបកម្មដំណើរការរៀបចំការបោះឆ្នោត ដោយអភិវឌ្ឍន៍ការចុះឈ្មោះបោះឆ្នោតតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានជាជំនួយដល់ការរៀបចំ និងការគ្រប់គ្រងការបោះឆ្នោត ជាអាទិ៍ ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ការចេញឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត (ឯ.អ.) ការគ្រប់គ្រងសំណុំរឿង និងរបាយការណ៍ពាក់ព័ន្ធនឹងពាក្យបណ្តឹង និងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ហើយរាល់ព័ត៌មាននិងឯកសារពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោត ត្រូវបានបង្ហោះនៅលើគេហទំព័រ គ.ជ.ប www.nec.gov.kh និង Mobile App។

៩៥-សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ មានគណបក្សនយោបាយចំនួន ១៨ បានចូលរួមប្រកួតប្រជែង និងមានចំនួនអ្នកបោះឆ្នោតបានទៅបោះឆ្នោតសរុបចំនួន ៨ ២១៤ ៤៣០នាក់ ស្មើនឹង ៨៤,៥៩% ។ ការបោះឆ្នោតក្នុងឆ្នាំ២០២៣ ត្រូវបានមតិជាតិនិងអន្តរជាតិ វាយតម្លៃថា បានប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិភាព សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈល្អ គ្មានអំពើហិង្សា គ្មានការគំរាមកំហែង ប្រកបដោយភាពរលូន មានតម្លាភាព សេរី ត្រឹមត្រូវ យុត្តិធម៌ ស្របតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ហើយត្រូវបានរៀបចំកាន់តែល្អប្រសើរឡើង ទាំងលើទិដ្ឋភាពច្បាប់និងទិដ្ឋភាពបច្ចេកទេស។

**III. បញ្ហាប្រឈម**

៩៦-ការផ្ទុះឡើងនៃជំងឺកូវីដ-១៩ និងឥទ្ធិពលនៃការវិវត្តដ៏ស្មុគស្មាញនៃសភាពការណ៍តំបន់និងអន្តរជាតិ បានបង្កជាឧបសគ្គយ៉ាងធំធេងសម្រាប់ពិភពលោកទាំងមូល រួមទាំងប្រទេសកម្ពុជា ក្នុងការកសាងនិងអភិវឌ្ឍជាតិ ជាពិសេស ការអនុវត្តអនុសាសន៍សិទ្ធិមនុស្សទាំងឡាយ ដែលបានទទួលយកនាពេលកន្លងមក។

៩៧-គុណភាពធនធានមនុស្សនៅមានកម្រិត ដែលទាមទារនូវការបន្តជំរុញសន្ទុះនៃការអភិវឌ្ឍធនធានមនុស្ស និងការកសាងមូលធនមនុស្សប្រកបដោយគុណភាព ដែលអាចធានានូវភាពរឹងមាំនៃសេដ្ឋកិច្ចជាតិ ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ការចាប់យកបច្ចេកវិទ្យា ការបន្សាំបច្ចេកវិទ្យា និងនវានុវត្តន៍។

៩៨-ស្ថាប័នសាធារណៈទោះបីមានការកែលម្អជាបណ្តើរៗ ប៉ុន្តែ នៅមិនទាន់មានប្រសិទ្ធភាពខ្ពស់គ្រប់គ្រាន់នៅឡើយ។ គុណភាពនិងសមត្ថភាពស្ថាប័នមានសារៈសំខាន់ ក្នុងការបង្កើនប្រសិទ្ធភាពនៃការរៀបចំ និងការអនុវត្តគោលនយោបាយ ឬផែនការសកម្មភាពផ្សេងៗ ដែលចាំបាច់ត្រូវបន្តលើកកម្ពស់និងពង្រឹបន្ថែម ដើម្បី

កសាងស្ថាប័នរឹងមាំសម្រាប់អភិវឌ្ឍលើគ្រប់វិស័យ។

**៩៩**-ទោះបីមានការកែលម្អមួយកម្រិតធំ ប្រព័ន្ធសុខាភិបាលនៅមានបញ្ហាប្រឈមដែលទាមទារត្រូវដោះស្រាយក្នុងស្មារតីបុរេសកម្ម បន្ទាន់ ជាប្រចាំនិងជាប់មិនដាច់ ព្រមទាំងការគិតគូរកែលម្អ និងអភិវឌ្ឍបន្ថែមលើគ្រប់ទិដ្ឋភាពទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ អភិបាលកិច្ច ធនធានមនុស្ស និងជំនាញវិជ្ជាជីវៈប្រកបដោយ សីលធម៌ខ្ពស់។

**១០០**-ដោយសង្គមមានការវិវឌ្ឍទៅមុខយ៉ាងឆាប់រហ័ស តម្រូវឱ្យមានការធ្វើវិសោធនកម្មច្បាប់ និងការកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ដែលនាំឱ្យសាធារណជនពិបាកក្នុងការតាមដាន ស្វែងយល់ និងអនុវត្តឱ្យបានត្រឹមត្រូវ ស្របតាមស្មារតីនៃលិខិតបទដ្ឋានគតិយុត្តទាំងនោះ។ ម្យ៉ាងវិញទៀត ការធ្វើវិសោធនកម្ម ឬការបង្កើតច្បាប់ថ្មីៗលើវិស័យមួយចំនួន មានជាប់ពាក់ព័ន្ធនឹងកត្តាប្រពៃណី ទំនៀមទម្លាប់ ផ្នត់គំនិត និន្នាការតំបន់និងអន្តរជាតិ ដែលត្រូវការការចូលរួមគ្រប់ភាគីនិងពេលវេលាបន្ថែមទៀត។

## IV. សេចក្តីសន្និដ្ឋាន

**១០១**-ព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តអនុសាសន៍សិទ្ធិមនុស្សទាំង ១៧៣ ដែលបានទទួលយកយ៉ាងខ្ជាប់ខ្ជួន។ អនុសាសន៍ទាំងនោះ ត្រូវបានបែងចែកទៅឱ្យក្រសួង/ស្ថាប័នមានសមត្ថកិច្ចដើម្បីអនុវត្តស្របតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ច្បាប់ កតិកាសញ្ញា អនុសញ្ញា និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដែលកម្ពុជាជារដ្ឋភាគី។ ទោះបីជាស្ថិតនៅក្នុងស្ថានភាពដ៏លំបាក ដែលបង្កឡើងដោយជំងឺកូវីដ-១៩ និងវិបត្តិផ្សេងៗទាំងក្នុងតំបន់និងអន្តរជាតិ ក៏កម្ពុជានៅតែខិតខំជម្នះគ្រប់ឧបសគ្គក្នុងការអនុវត្តអនុសាសន៍ទាំងអស់យ៉ាងយកចិត្តទុកដាក់ ក្នុងន័យជំរុញការលើកកម្ពស់និងការការពារសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា។ ជារួម អនុសាសន៍ភាគច្រើន ត្រូវបានក្រសួង/ស្ថាប័នមានសមត្ថកិច្ចអនុវត្តនិងទទួលបានលទ្ធផលគួរជាទីមោទនៈ និងមានអនុសាសន៍មួយចំនួនតូចប៉ុណ្ណោះ ដែលការអនុវត្តត្រូវធ្វើឡើងជាជំណាក់កាលៗ និងទាមទារពេលវេលាបន្ថែមទៀត។ បញ្ហាខ្វះខាតខ្លះនេះ គឺជាគោលការណ៍ទូទៅនៃសិទ្ធិមនុស្ស ដែលសិទ្ធិទាំងអស់ត្រូវពឹងអាស្រ័យគ្នាទៅវិញទៅមក និងជាសច្ចភាពដែលគ្មានប្រទេសណាមួយអាចអនុវត្តបាន ឬបំពេញកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិបានល្អឥតខ្ចោះទាំងស្រុងនោះទេ៕

# ឯកសារយោង


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- កតិកាសញ្ញា និងអនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលកម្ពុជាជារដ្ឋភាគី
- ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
- ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨
- ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសហជីពឆ្នាំ២០២០
- ច្បាប់ស្តីពីគណបក្សនយោបាយ
- ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា
- យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា
- របាយការណ៍ UPR ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា
- របាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា ឆ្នាំ២០១៨-២០២២
- ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣